អំពីប្រាសាទខ្លះនៅទីអង្គរ

PAR

ព្រះគ្រូសំឃវិជ្ជា ហ. តាត

PHNOM PENH

1928

bibliotheca Khmerica
Liberté • Égalité • Fraternité
RÉPUBLIQUE FRANÇAISE
BIBLIOTHEQUE NATIONALE DU CAMBODGE
NATIONAL MUSEUM OF CAMBODIA

Le contenu des ouvrages reproduits dans la collection Bibliotheca Khmerica n'engage en rien l'ambassade de France au Cambodge ni le ministère français des Affaires étrangères et européennes.

(2e exemplaire)

អំពីប្រាសាទខ្លះនៅទិអង្គរ

M. 1841

សៀវភៅសំគាល់ខ្លួន

ព្រះគ្រូសំឃរវិជ្ជ ហ. តាត

អាចារ្យបង្រៀនសិស្សនៅសាលាជាប្លីតាន់ខ្ពស់ ក្រុងភ្នំពេញ

ជានតែងនិងរៀបរៀង

ក្នុងសេចក្តីទុំនុកបំរុងនៃព្រះរាជបណ្ណាល័យ កម្ពុជា



ពុទ្ធសករាជ ២៤៧០

G. 702.4

QUELQUES MONUMENTS D'ANGKOR

GUIDE

RÉDIGÉ SOUS LES AUSPICES DE LA BIBLIOTHÈQUE ROYALE DU CAMBODGE

PAR

PRÉA KROU SANGVICHÉA H. TATH

PROFESSEUR DE SANSCRIT

A

L'ÉCOLE SUPÉRIEURE DE PALI A PHNOM-PENH



BIBLIOTHÈQUE CENTRALE DU CAMBODGE
N° 9006

PHNOM-PENH
IMPRIMERIE DU GOUVERNEMENT
1928

មាតិកា

ទំព័រលេខ

សេចក្តីផ្តួចផ្តើមសំណេរ ស្ទ-ហ្វីណូត ១

សេចក្តីអធិប្បាយរបស់នាងស្ត្រី ស៊ុយសានការប៉ែខ្សែ ៣

ភាសាផ្សេងៗ ៦

សេចក្តីរៀបរយនឹងសេចក្តីបេះដឹងក្នុងប្រទេសឥណ្ឌៀ ដែលធ្វើឲ្យចូលមកឥណ្ឌូស៊ីន

ពេរពីឈ្មោះទីអង្គរ ៨

សៀវភៅរឿងអង្គរ ១០

ការចាត់ចែងរៀបចំទីអង្គរ ១១

រឿងព្រេង ១១

ឈ្មោះស្តេចដែលជាឧកញ៉ាងទីអង្គរ ១៧

លទ្ធិសាសនា ១៩

សេចក្តីនាំផ្លូវទៅកាន់ទីអង្គរ

ដំណើរទៅអង្គរ ២៧

អង្គរវត្ត ៣១

ភ្នំបាក់ខែង ៤៩

អង្គរធំ ៥៣

បាយ័ន ៥៧

ពញ្ញ ៦២

ទីព្រះលានស្តេច ៦៤

វិមានអាកាស ៦៥

ទីលានស្តេចគម្ងាំ ៦៧

ទំព័រលេខ

ទេពប្រណម្យ ៦៨
ព្រះជាលិកៀ ៦៩
ព្រះពីឆ្នូរ ៧០
ឃ្លាំង ៧១
ប្រាសាទតាកែវ ៧២
ប្រាសាទតាព្រហ្ម ៧៤
ប្រាសាទបន្ទាយក្តី ៧៨
ស្រះស្រែង ៨១
ប្រាសាទក្រែកភ្ញា ៨២
ប្រាសាទប្រែរូប ៨៤
ប្រាសាទតាសោម ៨៦
ប្រាសាទក្រែលពោ ៨៧
ប្រាសាទតាគត់ធ្នូ ៨៨
ប្រាសាទព្រះខ័ន ៩២

ជាក់រូបថត

លេខរៀងរូបថត

ផែនទីអង្គរ ១
អង្គរវត្តតាមគំនូរបស់មោនសៀរ ដឺ ឡា ពារត៍ ២
ផែនទីអង្គរវត្ត ៣
អង្គរវត្ត វេលាមុនខាន់កាប់ផ្តាច្រែ ៤
អង្គរវត្ត វេលាទើបនឹងកាប់ផ្តាច្រែហើយ ៥
ផែនទីអង្គរធំ ៦
ហ្វាងទ្វារគេសាងទុំស្សធិស៍សាសនាព្រាហ្មណ៍នៅជាយ័ន ៧
ហ្វាងទ្វារគេសាងទុំស្សធិស៍សាសនាព្រាហ្មណ៍នៅប្រជុំអង្គរ ៨
រូបក្បាងពុទ្ធសាសនាប៉ែកខាងមហាយាន នៅប្រជុំអង្គរ ៩
ហ្វាងទ្វារគេសាងទុំស្សធិស៍ពុទ្ធសាសនាប៉ែកខាងមហាយាននៅប្រជុំអង្គរ . . ១០

TABLE DES MATIÈRES

Pages.

Dédicace ๑
Avant-Propos par Suzanne Karpelès ๓

INTRODUCTION

Influence de la civilisation de l'Inde en Indochine ๖
Renommée des ruines d'Angkor ๘
Quelques ouvrages relatifs aux ruines d'Angkor ๑๐
Conservation des ruines d'Angkor ๑๑
Légende relative à la fondation d'Angkor ๑๑
Noms de quelques rois qui ont fait construire de grands monuments dans le groupe d'Angkor ๑๗
Les religions dans l'ancienne capitale de l'Empire khmer ๑๘

GUIDE AUX RUINES D'ANGKOR

Moyens de communication ๖๗
Angkor Vat ๗๑
Phnôm Bakhèng ๘๘
Angkor Thom ๘๓
Bayon ๘๗
Bapuon ๖๖
Terrasse Royale ๖๘
Phimeanakas ๖๘
Terrasse du Roi Lépreux ๖๗
Tép-Pranam ๖๘
Prah Palilay ๖๘
Prah Pithu ๗๐
Khléang ๗๑
Ta Kéo ๗๖
Ta Prohm ๗๘
Bantéai Kedei ๗๘
Srah Srang ๘๑
Krâvanh ๘๖
Prê Rup ๘๘
Ta Som ๘๖
Krol Kô ๘๗
Néak Pean ๘๘
Prah Khan ๘๙

TABLE DES PLANCHES

	Pl.
Plan du groupe d'Angkor	๑
Angkor Vat, d'après une composition de Monsieur DELAPORTE, explorateur	๒
Plan d'Angkor Vat	๓
Angkor Vat avant le débroussaillement	๔
Angkor Vat dernier aspect	๕
Plan d'Angkor Thom	๖
Fronton brahmanique (Bayon)	๗
Fronton brahmanique (groupe d'Angkor)	๘
Bronze mahâyâniste (groupe d'Angkor)	๙
Fronton mahâyâniste (groupe d'Angkor)	๑๐

យើងសូមផ្ញើនសៀវភៅជាជំបូងនេះ

ដែលនិយាយអំពីសេចក្តីនាំផ្លូវទៅកាន់ប្រាសាទបូរាណ

ក្នុងស្រុកខ្មែរ ជាលោក ល្វី-ហ្វីណូត

ដែលលោកបានធ្វើការជាច្រើនដោយសេចក្តីប្រឹងប្រែង

ហើយនឹង

បានរិះរកដើម្បីនាំអ្នកទាំងពួងឲ្យដឹងនូវពង្សាវតារខ្មែរ

បរិយាយដើម

សេចក្តីដែកនាំផ្លូវទៅកាន់អង្គរនេះជាសៀវភៅ ១ ដំបូងក្នុងពួកសៀវភៅដែលព្រះរាជបណ្ណាល័យបំរុងនឹងបោះពុម្ព សៀវភៅនេះមានប្រយោជន៍ដើម្បីធ្វើឲ្យខេមរជាតិទាំងអស់គ្នាបានដឹងស្គាល់នៅប្រាសាទបូរាណផ្សេង ៗ ដែលមាននៅក្នុងស្រុកខ្មែរ ។

យើងមានសេចក្តីសង្ឃឹមថាគេនឹងយល់ជាប្រាកដ ថាពិតមែនតែមានបូរាណស្ថានខ្លះ ដែលបាក់បែកគ្រឹគ្រាអន្តរាយទៅអស់ ប៉ុន្តែប្រាសាទដែលបាក់បែកទាំងនោះ គួរជាទីកោតខ្លាចស្បប់ស្ងែងបាន ។

ឬ ១ ដុំ ៗ ដែលបន្តុបទ្បើងជាគេហស្ថាននោះធ្វើឲ្យឃើញសេចក្តីព្យាយាមនឹងសេចក្តីឆ្លៀយហត់ ដែលជាតិខ្មែរជាន់ដើមបានខំប្រឹង ដើម្បីករសាងជាប្រាសាទសម្រាបជាកិត្តិយស កិត្តិសព្ទរបស់ស្រុកខ្មែរ ។

ឬ ១ ដុំ ៗ មានអំណាចគួរឲ្យជាតិខ្មែរទាំងអស់សព្វថ្ងៃនេះគោរព់កោតខ្លាច ។

ហើយក្បាច់បំភ្លាក់ឯមួយ ។ ធ្វើឲ្យឃើញសៅគំនិតរបស់មនុស្សដែលបានជឹកនាំដៃកធ្លាក់ខ្សែត់លើឬ ដើម្បីធ្វើជារូបរឿងរ៉ាវ ឬក្បាច់អ្វី ។ ដែលនាំឲ្យអ្នកដែលបានឃើញស្រប់ស្រែងទាំងអស់ ។

ក្បាច់បំភ្លាក់ ១ ទង ។ នោះគួរជាទីធ្ងល់ដល់ជាតិខ្មែរក្មេង ។ ក្នុងជាន់ក្រោយណាស់ ។

យើងមានសេចក្តីសង្ឃឹមថា សេចក្តីនាំផ្លូវទៅកាន់អង្គរនេះ ធ្វើឲ្យជាតិខ្មែរទាំងអស់ ដែលបានមើលជឹងសេចក្តីមានបំណងប្រាប្ញាឆ្ងាយទៅមើលអ្វីទីប្រាសាទ ដែលបាក់បែកនោះ ហើយនឹងបានពិចារណាឃើញ មិនត្រឹមតែសេចក្តីខ្ពង់ខ្ពស់របស់ឥតរទេ ថែមទាំងមានសេចក្តីរីករាយសេចក្តីស្រណោះនឹងកាព្យឃ្លាង បណ្តាលកើតឡើងអំពីទីក្រុងចាស់ស្ងាត់ទៅទៀតផង ។

សុយសាឥការបីឡែស

អ្នកត្រួតត្រួតព្រះរាជបណ្ណាល័យ

ពាក្យប្រារព្ធ

សៀវភៅនេះដែលយើងបានរៀបចំធ្វើឡើងគឺធ្វើតាមគំនិតម៉ាដឹមួរអាហ្សែល ការប៊ុខ្សែស អ្នកគ្រប់គ្រងទីព្រះរាជបណ្ណាល័យដោយយល់ឃើញថានឹងមានប្រយោជន៍ដល់អ្នកស្រុកអាយក្នុងការដែលនឹងទៅមើលទីអង្គរ (នគរ) ជាដំណែលបូរាណស្ថានយើងមានបំណងចង់ឲ្យអ្នកដែលទៅមើលនោះ បានស្គាល់ផ្លូវដែលបូលទៅកាន់ទីបូរាណស្ថាននិមួយៗនឹងឲ្យបានដឹងរឿងរ៉ាវក្នុងទីអង្គរនោះខ្លះផង ព្រោះទីអង្គរនោះបើអ្នកដែលបូលទៅមើលមិនបានសង្កេតមើលដោយសព្វគ្រប់បេះតែដើរមើលទៅៗក៏ឥតមានដឹងអ្វីឡើយ គ្រាន់តែដឹងថាគេធ្វើនឹងឬមានក្បាប់ល្អណាស់ប៉ុណ្ណោះ បើខំសង្កេតពិនិត្យមើលទៅក៏អាចដឹងរឿងរ៉ាវខ្លះ ដោយមានរូបបម្លាក់នឹងសិលាចារឹកនៅទីនោះ តែក៏គង់ដឹងបានដោយកម្រ ព្រោះហេតុនេះបានជាយើងរៀបចំធ្វើសៀវភៅនេះឡើង តែដែលធ្វើនេះក៏មិនបានធ្វើដោយសព្វទឹកន្លែងបូរាណស្ថានទេ ធ្វើតែកន្លែងណាដែលគួរនឹងនាំមកថ្លែងហើយជាសេចក្តីសង្ខេបផង

ដើម្បីគាន់តែជាគ្រឿងប្រដាប់សំរាបនឹងជីកនាំផ្លូវអស់អ្នក ដែលត្រូវការនឹងទៅមើលអង្គរ ទៅបានដោយដាយ ។

ឯទីអង្គរនោះគួរតែអ្នកទាំងឡាយ នាំគ្នាទៅមើលកុំឲ្យខាន ព្រោះជាប្រាសាទទាំងប៉ុន្មាន ដែលមាននៅក្នុងទីនោះ ទោះជារបស់ចាស់បាក់បែកក៏ពិតមែន ប៉ុន្តែគង់នៅឃើញស្នាដៃរបស់លោក ដែលការសាងក្នុងជាន់មុនយូរហើយនោះ ជាជារបស់អស្ចារ្យគួរឲ្យស្ងើចដល់អស់ចិត្តយើងរាល់គ្នា ។

ទីអង្គរនោះ បើអ្នកដែលមានប្រាជ្ញាបានទៅឃើញហើយ បានពិនិត្យមើលដោយសព្វគ្រប់ ក៏គង់ដឹងថាក្នុងសម័យដែលគេការសាងប្រាសាទនោះ ស្រុកខ្មែរយើងនេះជាស្រុកបរិបូណ៌ដោយទ្រព្យសម្បត្តិ នឹងមនុស្សមានចំណេះវិជ្ជាប្រើនទាំងមហាក្សត្រិយ៍ក្នុងជាន់នោះក៏មានបុណ្យមានតេជានុភាពជាប្រើន មិនមែនដឹងតែត្រឹមនេះទេ្បីយ នឹងអាចដឹងដល់ទៅសាសនា ដែលមាននៅក្នុងជាន់នោះផង គឺដឹងថាមនុស្សក្នុងជាន់នោះ កាន់សាសនាដូច្នេះៗ ដោយមានរូបបម្លាក់ ហើយនឹងសិលាចារឹកជាគ្រឿងតិកតាងសំរាបពិចារណាឲ្យឃើញពិតប្រាកដបាន ។

ព្រោះហេតុនេះ យើងសូមឥណាឥតីសេចក្តីរៀបរយនឹងសេចក្តីបេះដឹង ព្រមទាំងលទ្ធិសាសនា ដែលផ្សាយចូលមកក្នុងស្រុកខ្មែរនេះជាសេចក្តីខ្លី ៗ ដើម្បីនឹងបានជាគ្រឿងប្រដាប់ប្រាជ្ញាឲ្យបានភ្លឺខ្លះ ដូចសេចក្តីតរទៅនេះ ។

កាលក្នុងរវាងពុទ្ធសករាជ ៦៥០ សេចក្តីរៀបរយនឹងសេចក្តីបេះដឹងក្នុងស្រុកឥណ្ឌៀគឺមជ្ឈិមបទេស ផ្សាយចូលមកក្នុងស្រុកឥណ្ឌាស៊ីន គឺស្រុកដែលស្ថិតនៅបន្ទោះស្រុកឥណ្ឌៀ នឹងស្រុកបិណ គឺស្រុកជ្វា ភូមា សៀម ខ្មែរ លាវ កូសាំងស៊ីន អណ្ណាម នឹងស្រុកតុងកាំង ។ល។ លុះដល់មកក្នុងរវាងពុទ្ធសករាជ ៨៥០ ស្រុកដែលនៅខាងត្បូងទន្លេមេកុង ឬទន្លេធំ គឺស្រុកលាវ ខ្មែរ កូសាំងស៊ីន ជាស្រុកទៅមកកាន់គ្នាជាមួយនឹងស្រុកបិណហើយនឹងស្រុកឥណ្ឌៀ ម្ល៉ោះហើយអស់ទាំងរបៀបអក្សរ នឹងលទ្ធិសាសនាទាំង ២ គឺសាសនាព្រាហ្មណ៍ នឹងពុទ្ធសាសនាខាងមហាយាន ដែលមានទៅក្នុងស្រុកឥណ្ឌៀ ក៏ផ្សាយចូលមកក្នុងស្រុកទាំងនោះ លុះដល់មកក្នុងរវាងពុទ្ធសករាជ ១១៥០ ស្រុកខ្មែរនេះក៏កើតមានសេចក្តីរុងរឿងបំរើនឡើង ដោយទ្រព្យសម្បត្តិ

នឹងចំណេះវិជ្ជាទាំងក្សត្រិយ៍ដែលសោយរាជក្នុងព្រះនគរ ក៏មានបុណ្យមានអានុភាពជាប្រើន ឥតមានសត្រូវណានឹងមកឥរតាំងបានឡើយ តែងមានជ័យជំនះឈ្នះអស់សត្រូវទាំងពួង ក្នុងសម័យនោះហើយដែលស្តេចក្នុងស្រុកខ្មែរ បានតាំងប័ឋករសាងទីក្រុងនៅខាងជើងទន្លេសាប មានប្រាសាទល្អៗ ជាប្រើនហើយ បានការសាងទាំងទេវស្ថាននឹងវិហារស្ថានជាប្រើនកន្លែង ដើម្បីនឹងទុទ្ទិសប្រទ្ធិយដល់សាសនាព្រាហ្មណ៍ខ្លះ ដល់ព្រះពុទ្ធសាសនាខាងមហាយានខ្លះ ទីទាំងអស់នោះហើយដែលគេហៅជាទីអង្គរសព្វថ្ងៃនេះ ស្តេចដែលនៅគ្រប់គ្រងទីអង្គរបានការសាងប្រាសាទជាប្រើននោះមិនតែស្តេច ១ ព្រះអង្គឡើយ គឺស្តេចប្រើនព្រះអង្គតរៗ គ្នាមក ប៉ុន្តែស្តេចទាំងនោះមានសេចក្តីប្រកាន់លទ្ធិសាសនាផ្សេងៗពីគ្នា ខ្លះគោរព់ខាងពុទ្ធសាសនាបំណែកមហាយាន ខ្លះគោរព់ខាងសាសនាព្រាហ្មណ៍ ប៉ុន្តែស្តេចទាំងនោះសុទ្ធតែមានរាជានុភាពប្រើនសឹងតែគ្រប់ព្រះអង្គ ព្រោះហេតុនោះបានជាក្នុងកាលឥឡូវនេះ គេបានឃើញសិលាចារឹកនៅទីអង្គរនោះ ខ្លះជាភាសាសំស្ក្រឹត ខ្លះជាភាសាអ្នកស្រុកធម្មតាតែជាអក្សរខ្មែរបូ-

ភាណ សិលាចារឹកដែលជាភាសាសំស្កឹត និយាយសរសើរពី បុណ្យស្តេចជាសុទ្ធតែទេពប្បុត្ត គឺទេវតាបុះមកកើត សិលាចារឹក ដែលជាភាសាអ្នកស្រុកធម្មតា និយាយពីការល្អ ៗ ដែលស្តេច បានសាងទុកមក ។

តរអំពីនេះទៅយើងសូមពណ៌នាដោយសង្ខេប ពីសេចក្តី ផ្សេង ៗ បំពោះរឿងអង្គរនេះទៀត ដូចមានរបៀបមាតិកាខាង ក្រោយនេះ ។

១ ពីកេរត៍ឈ្មោះទីអង្គរ ។
២ ពីសៀវភៅរឿងអង្គរ ។
៣ ពីការចាត់ចែងរៀបចំទីអង្គរ ។
៤ ពីរឿងព្រៃង ។
៥ ពីឈ្មោះស្តេចដែលបានការសាងទីអង្គរ ។
៦ ពីលទ្ធិសាសនា ។

កេរត៍ឈ្មោះទីអង្គរ — កេរត៍ឈ្មោះទីអង្គរសព្វថ្ងៃនេះផ្សាយទៅគ្រប់ ប្រទេសទាំងអស់ក្នុងលោក មានប្រទេសអ្រ៉ូប៉ីនិងប្រទេសអាស៊ី ជាដើម មនុស្សនៅក្នុងប្រទេសទាំងអស់នោះ គេបានដឹងរឿង

អង្គរនេះប្រាកដជាក់ស្តែងហើយ ដោយគេមានសៀវភៅរឿងអង្គរធំឯរូបឋិតទីអង្គរដំកល់ទុកនៅសារមន្ទីរ គឺរោងសំរាបដំកល់របស់ប្លាណា ធំឯបណ្ណាល័យ គឺទីសំរាបដំកល់គម្ពីរដីកា ធំឯក្សត្រប្បាប់ សូម្បីក្នុងសាលារៀន ក៏មានសៀវភៅរឿងអង្គរនេះដែរ ។

សៀវភៅរឿងអង្គរ – សៀវភៅដែលគេតែងពីរឿងអង្គរ ជាដំបូងមុនគេបំផុតក្នុងប្រទេសអាស៊ី គឺសៀវភៅដែលកើតឡើងដោយស្នាដៃបិណម្នាក់ឈ្មោះចាវ-តា-កួន ជារាជទូតស្តេចស្រុកបិណ។ បានបញ្ជូនមកស្រុកខ្មែរ ដែលបិណគេហៅតាមភាសាគេថា ស្រុក ចេន-ឡា ហើយរាជទូតនោះឯងបានដើរមើលក្នុងទីអង្គរដោយសព្វគ្រប់ ទើបបានទៅតាក់តែងធ្វើជាសៀវភៅ ១ ពីរឿងអង្គរក្នុងពុទ្ធសករាជ ១៨៣៨ ។

មានសៀវភៅ ១ ទៀត អំពីរឿងអង្គរដូចគ្នា កើតឡើងជាដំបូងមុនគេខាងប៉ែកប្រទេសអ៊ូរ៉ុប ដោយស្នាដៃអ្នកប្លូសក្នុងសាសនាគ្រិស្ត ១ នាក់ អ្នកប្លូសនោះបានមកមើលទីអង្គរ ហើយបានទៅតាក់តែងធ្វើជាសៀវភៅ ១ ក្នុងពុទ្ធសករាជ ២១៤៧ ។

ប្រមាណជា ១០០ ឆ្នាំមកហើយ មានអ្នកជំណើរជា
ច្រើនមកមើលទីអង្គរ ហើយបានឋិតបានតិត្យមើលទីអង្គរនោះ
ហើយបានធ្វើជាសៀវភៅឡើងជាច្រើន ឯអ្នកជំណើរទាំងនោះ
ច្រើនតែជាតិបារាំងសែស ជាតិឯទៀត ៗ ក៏មានដែរប៉ុន្តែតិច ។

ការចាត់ចែងរៀបចំទីអង្គរ – បំនួន ២៥ ឆ្នាំមកហើយ រាជការបានធ្វើ
ផ្មែកផ្តាំក់ការរៀបចំទីអង្គរទាំងមូល ទៅលើសាលាបារាំងសែស
អេកស្តែមអ្វរិយង់ នៅទីក្រុងហាណូយក្នុងដែនតុងកាំង នោះ
សាលាបារាំងសែស ក៏បានទទួលការចាត់ចែងរៀបចំទីអង្គរនោះ
ឲ្យបានស្អាតល្អឡើងវិញ មានរៀបទីផ្លូវក្នុងអង្គរនោះជាដើម
ដរាបដល់មកសព្វថ្ងៃនេះ ។

រឿងព្រេង[1] – កាលក្នុងពុទ្ធសករាជ ៦០០ មានបិណ ១ នាក់
ឈ្មោះលិមសេង នៅស្រែកសង់ហាយ បិណានោះជាខ្ញុំគេដោយ
សារជំពាក់ប្រាក់គេ ៦ ណែន ។

ហាមានកាល ១ ថ្ងៃ មាននាងទេវធិតា ៥ នាក់នៅស្ថានព្រះ
ឥន្ទ្រ ចូលមកលេងក្នុងសួនផ្ការបស់លិមសេង ក្នុងពួកនាងទេវ

(១) នែលហៅថារឿងព្រេង គឺរឿងនែលគ្រាន់តែឮតរ ៗ គ្មានមក នឹងសង្កេតរកដើមហេតុ
នៃរឿងនោះឲ្យច្បាស់ម៉ឺនជាន ។

ធីតាទាំង ៥ នោះ មានតាងទេវធីតា ១ ឈ្មោះទិព្វសុតាបន្ទ បាន
បេះផ្កា ៦ ក្នុងសួននោះ ដល់ព្រះឥន្ទ្របានជ្រាបថាតាងទិព្វសុតា
បន្ទបេះផ្ការបស់លឹមសេងដូចនោះ ព្រះឥន្ទ្រក៏ជាក់ទណ្ឌកម្មដល់
តាងទិព្វសុតាបន្ទ ឲ្យបុះមកធ្វើជាប្រពន្ធលឹមសេង នៅស្ថាន
មនុស្សលោក ៦ ឆ្នាំ ។

តាងទិព្វសុតាបន្ទ ក៏បានមកជាប្រពន្ធ លឹមសេង ហើយ
លឹមសេងក៏បានទៅសូមខ្ចីប្រាក់ម្ចាស់បំណុលខ្លួន ៤ណែនបែម
ទៀត ដើម្បីនឹងយកទៅទិញស្លឹតយកមកឲ្យតាងទិព្វសុតាបន្ទ
ត្បាញជាសម្ពត់ លុះដល់តាងទិព្វសុតាបន្ទបានត្បាញជាសម្ពត់
រួចកាលណាហើយ លឹមសេងក៏យកទៅដូនម្ចាស់បំណុលខ្លួន
ម្ចាស់បំណុលក៏មានសេចក្តីត្រេកអរនឹងលឹមសេងហើយឲ្យប្រាក
ទៅលឹមសេង នឹងតាងទិព្វសុតាបន្ទ បំនួន ៥០ណែន ហើយឲ្យ
រូបទាំងប្រាកដែល លឹមសេង ជុំពាក់នោះផង លឹមសេង ក៏បាន
ធ្វើជាអ្នកមានឡើងដោយសារបំណែនប្រពន្ធ ។

លឹមសេង និងតាងទិព្វសុតាបន្ទ នៅជាមួយគ្នាបាន ១ ឆ្នាំ
ក៏មានកូនប្រុស ១ នាក់ កូននោះបេះគួរគំនួរយ៉ាងសំខាន់ណាស់

ដោយក្លួននោះឱស្សាហ៍ធ្វើការ នាងទិព្វសុតាបន្ទុ ក៏ឲ្យឈ្មោះក្លួននោះជាព្រះវិស្សុកម្ម[1] ។

នាងទិព្វសុតាបន្ទុ កាលបើដល់កំណត់រូបទោសទណ្ឌកម្ម ហើយ ក៏បេះផ្កា ៦ ដាក់លើខ្នើយរបស់ស្វាមី ហើយនាងក៏ហោះទៅស្ថានសួគ៌វិញទៅ ។

លឹមសេងនឹងព្រះវិស្សុកម្មរកនាងទិព្វសុតាបន្ទុពុំឃើញ ក៏មានសេចក្តីព្រួយ ។

កាលនោះស្តេចប្រទេសរាជ សោយរាជនៅក្នុងស្រុកខ្មែរ ស្តេចសុគតទៅមិនមានព្រះរាជបុត្រ នឹងសោយរាជតរៀងរ្យៅនោះឡើយ ។

ក្នុងថ្ងៃនោះមានទ្រមាក់ជំរឹ ១ នាក់ ឈ្មោះ ទា តាំជំរឹខ្លួនទៅលាងទឹកស្ទឹង ឈ្មោះទាក្រឡេកឃើញភាជន៍ ១ មានទាំងមាន់ស្វោរ ១ នៅក្នុងភាជន៍នោះផង អណ្តែតមកត្រង់ខ្លួនហើយក៏យកភាជន៍នោះទៅបង្ហាញលោកគ្រូមេរិត្ត ។ ក៏ស្តាប់រសអានុភាពមាន់នោះហើយលោកយកក្បាលមាន់ឆាន់ខ្លួនលោក[illegible]ហើយលោក

(១) ពាក្យនេះតាមទម្លាប់ដែលគេតែងហៅដោយតរៗ ក្នុងរឿងនេះថា ព្រះពិស្សុណុការ។

បែកសាច់ទ្រូងមាន់ឲ្យទៅឈ្មោះ ទា ត្រង់ភ្លៅមាន់ឲ្យទៅនាងវង ជាប្រពន្ធឈ្មោះ ទា តែលោកមិនឆ្ងាយប្រាប់ជាដូចម្តេចទៀយ ។

កាលក្រោយដែលបានស៊ីសាច់មាន់នោះឈ្មោះទាក៏បានធ្វើជាស្តេចសោយរាជក្នុងស្រុកខ្មែរ បំណែកខាងប្រពន្ធក៏បានធ្វើជាអគ្គមហេសីស្តេចនោះ នាងវងជាអគ្គមហេសី ក៏មានផ្ទៃពោះបានរាជបុត្រ ១ ឲ្យឈ្មោះថាព្រះកេតុមាលា ។

ព្រះវិស្សុកម្ម ក៏បេះតែដើរស្វែងរកមាតាជាដរាប មានកាល ១ ថ្ងៃព្រះវិស្សុកម្ម បានឃើញនាងទេវធីតាប្រើនតាក់ តាំគ្នាមកលេងកំសាននៅព្រៃភ្នំ ១ ព្រះវិស្សុកម្មក៏ពួនហើយអធិស្ឋានថា បើស្ត្រីទាំងនោះជានាងទេវធីតា ហើយព្រះមាតាខ្ញុំក៏មកជាមួយនឹងនាងទេវធីតាទាំងនោះដែរ នោះខ្ញុំសូមកុំឲ្យមាតាខ្ញុំហោះទៅជាមួយនឹងនាងទេវធីតាឯទៀតរូបឡើយ លុះអធិស្ឋានដូចនោះហើយក៏ស្ទុះទៅឯទីដែលនាងទេវធីតាមកលេងកំសាននោះ នាងទេវធីតាទាំងនោះក៏ហោះជាប្រញាប់ទៅ តែឯនាងទិព្វសុតាបន្ទុ ១ ហោះទៅមិនរួចព្រះវិស្សុកម្មក៏ស្ទុះទៅទាប នាងទិព្វសុតាបន្ទុ

ក៏ស្គាល់ថាព្រះវិស្សុកម្មជាកូនឯង ហើយសោយសោកពិលាប
ក្នុងទីនោះ រួចឯងឲ្យសម្តែងបង់ការរបស់ឯងទៅ ព្រះវិស្សុកម្ម
ស្បៃក ហើយឯងក៏ពព្រះវិស្សុកម្មហោះឡើងទៅតាមអាកាស
លុះទៅដល់ព្រះឥន្ទ្រក្បែកឃើញព្រះវិស្សុកម្ម ក៏ត្រាស់សួរទៅ
ឯងទើឲ្យសុតាបន្ទូលថា មនុស្សដែលឯងនាំមកក្នុងវិងអញនេះ តើ
ជាមនុស្សដូចម្តេច ឯងទើឲ្យសុតាបន្ទូលឆ្លើយថា ក្មេងនេះជាកូនខ្ញុំ
ម្ចាស កាលខ្ញុំទៅទៅស្ថានមនុស្សលោក យកលឹមសេងធ្វើជាប្តី
ព្រះឥន្ទ្រត្រាស់បង្គាប់ឲ្យហៅព្រះវិស្សុកម្មឲ្យមកសួរទៅគាល់ឯក្នុងប្រា-
សាទ ហើយបង្គាប់ឲ្យទេវបុត្របង្រៀនសិល្បសាស្ត្រព្រះវិស្សុកម្ម
អំពីនោះមកព្រះឥន្ទ្រអនុញ្ញាតសម្រេច ឲ្យព្រះវិស្សុកម្មបានជាអ្នក
បង្ហាត់បង្រៀនដល់មនុស្សទាំងប៉ុន្មានដែរកាន់សាសនាព្រះពុទ្ធ។

មានរាត្រី ១ ព្រះឥន្ទ្រហោះចុះមកឯស្រុកខ្មែរ មកចាប់បី
យកព្រះកេតុមាលហោះទៅឯស្ថានសួគ៌ ហើយត្រាស់បង្គាប់ឲ្យ
រៀបធ្វើបុណ្យ ដើម្បីនឹងឲ្យព្រះកេតុមាលបានព្រះជន្ម ៤០០ ឆ្នាំ
រួចឲ្យហៅព្រះកេតុមាលយាងទៅប្រាសាទទាំងប៉ុន្មានដែលមាន
នៅក្នុងស្ថានព្រះឥន្ទ្រ លុះដល់ព្រះកេតុមាលទៅសព្វគ្រប់ហើយ

ព្រះឥន្ទ្រក៏មានបន្ទូលទៅព្រះពោតុមាលាហ៊ាអញខ្សែនគរស្រុកខ្មែរឯង បើឯងឯងចង់សាងប្រាសាទខ្សែដូចប្រាសាទណាមួយដែលឯងឃើញនៅទីនេះ ប្រាប់យាយប្រាប់អញខ្សែត្រង់មកប្រុះអញនឹងប្រើជាង ១ នាក់ខ្សែទៅសាងឯនគរឯងខ្សែឯង ។

ព្រះពោតុមាលាទើបឆ្លើយថា ទូលបង្គំនជាខ្ញុំចង់សាងប្រាសាទខ្សែស្អ ដូចជាក្រោលគោរបស់ព្រះអង្គ ។

ព្រះឥន្ទ្រក៏ត្រាសខ្សែហៅព្រះវិស្សុកម្មប្ញូលមកគាល់ ហើយត្រាសបង្គាប់ទៅព្រះវិស្សុកម្ម ខ្សែទៅសាងប្រាសាទថ្វាយព្រះពោតុមាលា ។

ដល់ពុទ្ធសករាជ ៦២០ ព្រះវិស្សុកម្មបាច់សាងប្រាសាទនោះហើយផ្សាំ ១ មុកដែលនាំខ្សែដឹកាយទៅជាឬ ។

ព្រះពោតុមាលាទតឃើញកំពូលអង្គរ ដែលព្រះវិស្សុកម្មសាងនោះរៀបក៏ត្រាសបង្គាប់ខ្សែព្រះវិស្សុកម្ម ដម្រង់ខ្សែត្រង់ឡើងវិញ ។

ដល់ដំរូវក្រោយព្រះពោតុមាលាប្រទានដែក ៣ ហាបទៅព្រះវិស្សុកម្ម ត្រាសបង្គាប់ខ្សែព្រះវិស្សុកម្មយកដែកនោះទៅធ្វើជាព្រះ

ទំនង ១ ព្រះវិស្សុកម្មយកដៃកនោះទៅរំលាយយកតែខ្លឹមទៅធ្វើជា
ព្រះខ័នតួប ១ ។

ព្រះកេតុមាលាទ្រង់ខ្ចាល់ដោយទតទៅឃើញព្រះខ័នដែល
ព្រះវិស្សុកម្មសិទ្ធនោះតួបពេក ព្រះវិស្សុកម្មក៏ទឹងហើយគិតថាតំឯង
ដើរចេញពីស្រុកខ្មែរ ហើយក៏ដើរចេញអួសព្រះខ័នតាមក្រោយ
អំណាចឫទ្ធិព្រះខ័នដែលមុតជាបំផ្លែកអស្ចារ្យណាស់ ព្រះខ័ន
នោះក៏មុតក្តារជាប់ជា ២ ភាគ ព្រះកេតុមាលាឃើញព្រះខ័ននោះ
មុតជាអស្ចារ្យណាស់ ក៏គ្រាសបង្គាប់ឲ្យហៅព្រះវិស្សុកម្មមកវិញ
ហើយសួមព្រះខ័នពីព្រះវិស្សុកម្មផឹង ព្រះវិស្សុកម្មមិនព្រមថ្វាយ
ហើយយកព្រះខ័ននោះ ទៅចោលក្នុងទន្លេសាប រួចក៏រត់ទៅឯ
ស្រុកចិណាទៅ ។

ឈ្មោះស្តេចដែលបានការសាងទីអង្គរ — ព្រះនាមស្តេចដែលបានការសាង
ទីអង្គរនោះមានប្រើនព្រះអង្គ តែដែលនៅលក្នុងទីនេះបំពោះតែ
ស្តេចដែលមានកិត្តិយសធំៗដូចខាងក្រោយនេះ ។

ស្តេចជាធំបួងទ្រង់ព្រះនាម ជយវរ្ម័ន ទី ២ (ឃ្មេរស្វែ)[1]

---

(១) ព្រះនាមទាំងប៉ុន្មានក្នុងវង់ក្រចកនេះ ជាព្រះនាមដែលទ្រង់ទីវង្គត់ហើយ ។

សោយរាជក្នុងពុទ្ធសករាជ ១៣៤៥ ដល់ ១៤១២ ស្តេចនេះបានសាងទីអង្គរធំព្រមទាំងប្រាសាទបាយ័នធំនិងប្រាសាទឯទៀតខ្លះ។

ស្តេចទ្រង់ព្រះនាមយសោវរ្ម័ន (បរមសិវលោក) សោយរាជក្នុងពុទ្ធសករាជ ១៤៣២ ដល់ ១៤៥៣ ស្តេចនេះបានសាងទីអង្គរធំដែលហៅថា យសោធរបុរ ព្រមទាំងប្រាសាទបាយ័នដែលហៅថា យសោធរគិរិ ថែមទៀត ហើយបានសាងប្រាសាទនៅភ្នំបាក់ខែងដែលហៅថា យសោធរេស្វរ ។

ស្តេចទ្រង់ព្រះនាមហស៌វរ្ម័ន (រុទ្រលោក) សោយរាជក្នុងពុទ្ធសករាជ ១៤៥៣ ស្តេចនេះបានសាងបង្កើយប្រាសាទវិមានអាកាស ។

ស្តេចទ្រង់ព្រះនាមរាជេន្ទ្រវរ្ម័ន (សិវលោក) សោយរាជក្នុងពុទ្ធសករាជ ១៤៨៣ ដល់ ១៥១១ ស្តេចនេះបានសាងប្រាសាទមេបុណ្យខាងកើត និងប្រាសាទតាព្រហ្ម និងបន្ទាយក្តី ។

ស្តេចទ្រង់ព្រះនាមជយវរ្ម័ន ទី ៥ (បរមរីរលោក) សោយរាជក្នុងពុទ្ធសករាជ ១៥១១ ដល់ ១៥៤៤ ស្តេចនេះបានសាងប្រាសាទបាពួន ។

ស្តេចទ្រង់ព្រះនាមស្រីវរម័នទី ២ (បរមវិស្ណុលោក) សោយ
រាជក្នុងពុទ្ធសករាជ ១៦៥៥ ដល់ ១៦៩៥ ស្តេចនេះបានសាង
ក្បាច់រម្លាប់ព្រមទាំងសិលាចារឹកនៅជញ្ជាំងអង្គរវត្តជុំវិញឯទីប្រា-
សាទអង្គរវត្តទាំងមូល ព្រមទាំងក្បាច់បម្លាក់ដទៃ ៗ នៅទីអង្គរ
វត្តនោះប្រហែលជាស្តេចនោះលោកការសាងដែរ ។

លទ្ធិសាសនា — សាសនាដែលមាននៅទីអង្គរនោះ មាន ២
យ៉ាង គឺសាសនាព្រាហ្មណ៍ ១ សាសនាព្រះពុទ្ធឬពុទ្ធសាស-
នា ១ ។

សាសនាព្រាហ្មណ៍ គេប្រកាន់យកទេវតាជាធំ ជាទីរាប់
អានធ្វើនមស្សការបូជា គឺព្រះព្រហ្មជាអ្នកបង្កើតលោក វិស្ណុ គឺព្រះ
នារាយណ៍ ជាអ្នកថែរក្សាលោកឲ្យបានសេចក្តីសុខសេចក្តីក្សេម
សិរី គឺព្រះឥស្សរ ជាអ្នកបង្កើតលោក ទំាងជាអ្នកបំផ្លាញលោក
ហេតុនោះបានជាប្រាសាទទាំងប៉ុន្មានក្នុងទីអង្គរ ដែលគេទុំស្ស
ដល់សាសនាព្រាហ្មណ៍ ឥឡូវនេះគេបានឃើញរូបព្រាហ្មណ៍
ទំាងរូបព្រះនារាយណ៍ ទំាងសិវលិង្គ ជាជំនួសស្នងអង្គព្រះឥស្សរ
នៅប្រាសាទទាំងនោះ ។

ពុទ្ធសាសនា មាន ២ យ៉ាង គឺពុទ្ធសាសនាខាងមហាយាន ១ ពុទ្ធសាសនាខាងហីនយាន ១ ឯពុទ្ធសាសនាដែលមានក្នុងជាន់អង្គរនោះ គឺពុទ្ធសាសនាខាងមហាយាន ។ នេះគេប្រកាន់យកព្រះពោធិសត្វឈ្មោះអវិលោកិតេស្វរជាទីរាប់អានធ្វើនមស្សការបូជា ព្រោះហេតុនោះបានជាប្រាសាទទាំងប៉ុន្មានដែលគេទុទ្ទិស្សដល់ព្រះពុទ្ធសាសនា ឥឡូវនេះគេបានឃើញរូបអវិលោកិតេស្វរ នោះដោយប្រឹនៅក្នុងប្រាសាទទាំងនោះ ឯពុទ្ធសាសនាខាងហីនយាន នោះទើបនឹងមានក្នុងកាលជាខាងក្រោយទេ ។

ព្រះពុទ្ធសាសនាខាងមហាយាន មានលទ្ធិខុសធ្វើងគ្នានឹងពុទ្ធសាសនាខាងហីនយាន ដូចសេចក្តីដែលពោលដោយសង្ខេបតរទៅនេះ ។

១ អក្សរដែលមាននៅក្នុងគម្ពីរដីកា ប៉ែកខាងមហាយាន ជាអក្សរប្រើជាភាសាសំស្ក្រឹត ប៉ែកខាងហីនយាន ជាអក្សរប្រើជាភាសាបាឡី ។

២ ខាងមហាយានប្រកាន់ថាអ្នកកាន់ពុទ្ធសាសនា កាលបើមានបាបគ្រោះឬទុក្ខភ័យអ្វីកើតឡើង បើបានធ្វើអញ្ជលិកម្ម រលឹកដល់ពោធិសត្វដូចជាព្រះអវលោកិតេស្វរ ព្រះពោធិសត្វនោះនឹងមកជួយឲ្យរួចពីបាបគ្រោះឬទុក្ខភ័យនោះបាន ហើយអាចជួយបំរុងបំរើនដល់អ្នកកាន់ពុទ្ធសាសនា ឲ្យមានសេចក្តីសុខសួស្តីបាន ·បំណែកខាងហីនយាន ប្រកាន់ថាឥតមានអ្នកណានឹងជួយឲ្យរួចពីបាបគ្រោះឬទុក្ខភ័យទាំងពួងបានទេ ឥតមានអ្នកណានឹងជួយបំរុងបំរើនឲ្យបានសេចក្តីសុខ សេចក្តីបំរើនបានឡើយ ស្រេចតែកម្មជាកុសលនឹងអកុសលដែលខ្លួនធ្វើ បើធ្វើល្អនឹងបានល្អ ធ្វើអាក្រក់នឹងបានអាក្រក់ ។

ឯពួកមហាយាន នឹងហីនយានទាំងពីរនេះ កាលពីដើមក៏ជាពួកមួយជាមួយគ្នាដែរ តែដល់មកកាលជាខាងក្រោយ គឺក្រោយព្រះសម្មាសម្ពុទ្ធជាម្ចាស់ប្រហែលនិព្វានទៅ អ្នកកាន់ព្រះពុទ្ធសាសនាក៏បែកលទ្ធិគ្នាទៅជាពីរពួក គឺពួក ១ ដែលឃើញថាប្បាប់វិន័យនឹងសេចក្តីប្រតិបត្តិផ្សេង ។ ក្នុងព្រះពុទ្ធសាសនាគិង តែងណាស់ លំបាកនឹងប្រតិបត្តិតាមឲ្យសព្វគ្រប់ ក៏នាំគ្នាបន្ថែ

បន្តុយខ្លះចេញ ពួកនោះបានព្រមព្រៀងគ្នា ឲ្យឈ្មោះពួកខ្លួនជា មហាយាន ហើយឲ្យឈ្មោះពួកអ្នកដែលកាន់ព្រះពុទ្ធសាសនា ដោយគ្រប់គ្រាន់តាមទំនងដើមនោះជាហីនយាន ព្រោះហេតុ នោះពាក្យទាំងពីរនេះ ក៏មានហៅជាប់មកដរាប ដល់សព្វថ្ងៃ នេះ ។

ឯសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាខាងមហាយានដែរ នៅលាយប្រទ្បំគ្នាបានក្នុងជាន់អង្គរនោះ ព្រោះមានលទ្ធិស្មើរតែ និងប្រហែល ។ គ្នាខ្លះ សាសនាទាំង ២ នោះបានរុងរឿងក្នុងទីអង្គរ តាំងពីពុទ្ធសករាជ ១១៥០ ដល់ ១៨៥០ ។

ឯសេចក្តីរៀបរយ និងសេចក្តីលេងដឹងរបស់ខ្មែរ បំរើនរុងរឿងល្អឡើងបំផុត បានតែត្រឹមរវាងពុទ្ធសករាជ ១៨០០ តរពីនោះមក ក៏លេងតែបន្ថយបុះបង្គិចម្តងៗ ដោយហេតុមានពួកចាមដែលនៅស្រុកអណ្ណាមក្បែរមាត់សមុទ្រ ឬជ្វាឯណាក៏ពួកសៀមលើកទ្រព្យលុកលុយចូលមក ម្ល៉ោះហើយស្រុកខ្មែរក៏បានសេចក្តីអំបាកដដែរប្រឹង ទ្រព្យសម្បត្តិនិងបំណោះវិជ្ជាក្នុងស្រុក ក៏លេងតែបន្ថយបុះដោយលំដាប់ ទាំងស្តេចក្នុងព្រះនគរ ក៏បន្ថយព្រះរាជានុ-

ភាពមិនអាចនឹងគ្រប់គ្រងទឹនគរនោះបាន ហើយក៏លះបង់ចោល
ទឹនគរនោះដរាបដល់មកសព្វថ្ងៃនេះ ។

កាលក្នុងសម័យ ដែលសៀមលុកលុយចូលមកនៅក្នុង
ស្រុកខ្មែរនោះ បំណែកពុទ្ធសាសនាខាងហីនយាន ក៏ជាប់មកពី
ស្រុកសៀម មកមាននៅក្នុងស្រុកខ្មែរនេះ លុះតរៗមកពួកអ្នក
កាន់ពុទ្ធសាសនាខាងហីនយាន ក៏មានកំឡាំងក្លាហាន អាចធ្វើ
ឲ្យពួកអ្នកកាន់សាសនាព្រាហ្មណ៍ នឹងពុទ្ធសាសនាខាងមហា
យានចាយកំឡាំងប៉ះបន្ទប់មួងៗ ដរាបដល់មកសព្វថ្ងៃនេះ សាស-
នាទាំង ២ នោះ ក៏មិនប្រាកដឈ្នះក្នុងស្រុកខ្មែរនេះឡើយ ។

បំណែកអ្នកកាន់ពុទ្ធសាសនា ក្នុងស្រុកខ្មែរសព្វថ្ងៃនេះ
សុទ្ធតែខាងពួកហីនយានទាំងអស់ សាសនាខាងហីនយាននេះ
មិនមែនមានតែក្នុងស្រុកខ្មែរនេះទេ ស្រុកដែលនៅបំណែកទិស
ខាងត្បូង គឺស្រុកលង្កាភូមាមន សៀម លាវ សុទ្ធតែអ្នកកាន់ពុទ្ធ
សាសនាខាងហីនយានទាំងអស់ ហេតុនោះពួកខាងហីនយាន
នឹងហៅថាទក្ខិណនិកាយ ឬពួកខាងត្បូង ដូចនេះភិក្ខុក៏បាន
ឯបំណែកពុទ្ធសាសនាខាងមហាយានសព្វថ្ងៃនេះ ស្ថិតនៅក្នុង


បំណែកស្រែកទិសខាងជើង គឺស្រែកទីបេ ស្រែកចិណ ស្រែកយីប៉ុន
ហេតុនោះពួកខាងមហាយាន គឺឯហៅថាឧត្តរនិកាយ (ពួកខាង
ជើង) ដូចនេះវិញក៏បាន ។

យើងប្រុលបិត្តថាសាសនាព្រាហ្មណ៍គឺឯពុទ្ធសាសនាខាង
មហាយាន ដែលមាននៅក្នុងស្រែកខ្មែរពីដើម សព្វថ្ងៃនេះពិតជា
វិនាសបាត់ឈ្មោះទៅមែន តែត្រង់សេចក្តីប្រែកាន់លទ្ធិសាសនា
ទាំងពីរនោះគង់ជាប់មាននៅជិវាបមកដល់សព្វថ្ងៃនេះខ្លះ ដោយ
ឆ្លាប់ប្រែកាន់តរៗ គ្នាយូរមកហើយ អ្នកកាន់សាសនាសព្វថ្ងៃនេះ
ខ្លះដែលមិនដឹងដោយមិនបានស្គាប់ មិនបានរៀនសូត្រប្រែន
ក៏មិនយល់ថាសាសនាណាកាន់លទ្ធិដូចម្តេចនោះទៀយ ម្ល៉ោះ
ហើយក៏ប្រតិបត្តិប្រែកាន់លទ្ធិសាសនាដទៃៗ សំគាល់ថាជាព្រះ
ពុទ្ធសាសនា ដែលខ្លួនត្រូវកាន់ ដូចអ្នកខ្លះក្នុងស្រែកខ្មែរនេះ
ប្រែកាន់សេចក្តីរាប់អានគឺឯនមស្សការប្លូជាដល់ពួកទេវតាជាដើម
តាមលទ្ធិខាងសាសនាព្រាហ្មណ៍ តែមិនដឹងដូចនោះក៏ស្មានថា
ដែលទ្ធិខាងព្រះពុទ្ធសាសនា ហើយបេះតែនាំគ្នាប្រតិបត្តិធ្វើ
លាយប្រឡំជាមួយគ្នានឹងលទ្ធិខាងព្រះពុទ្ធសាសនា ។

យើងសង្ឃឹមថាបើអស់អ្នកកាន់ព្រះពុទ្ធសាសនា ដែលមិនទាន់បានជ្រាបពីរបៀបសាសនាក្នុងស្រុកខ្មែរនេះពីដើម ហើយត្រូវការបង់ដឹងបានទៅពិនិត្យមើលទីអង្គរ ដោយសព្វគ្រប់នោះគង់តែងបានជ្រាបមិនខានឡើយ ។

ក្នុងការរៀបបំផ្លើសៀវភៅនេះ យើងមានសេចក្តីអរគុណតែងអ្នកអង្គម្ចាស់ម៉ងតាណា ទីអនុមន្ត្រីដោយក្រែលែង ព្រោះលោកមានព្រះទ័យឈឺឆ្អាលបង់ឲ្យបានកើតសៀវភៅនេះ ហើយលោកបានមកជួយដោយកំឡាំងកាយ វាចា បិត្ត របស់លោកជារាបជាស់ហើយស្រេច ។

នៅទីបំផុតនេះ យើងសូមបំរែនូវសេចក្តីសុខសួស្តីគ្រប់ប្រការ ដល់ព្រះករុណាជាម្ចាស់ជីវិត ព្រះចៅក្រុងកម្ពុជាធិបតី តែងរាជការទំនុកបំរុងស្រុកខ្មែរ តែងអ្នកដើមគំនិតបង្កើតសៀវភៅនេះ តែងអ្នកជួយទំនុកបំរុងឲ្យកើតសៀវភៅនេះ ជារាបជាស់កាលជាអវិសានទៅហោង ꕥ—



ប្រាសាទអង្គរវត្ត តាមគំនូរបស់មោនសៀរ ឌីក្លាពាត់

សេចក្តីនាំផ្លូវទៅកាន់ទីអង្គរ (នគរ)

អំពីដំណើរទៅអង្គរ

ដំណើរដែលទៅអង្គរសព្វថ្ងៃនេះ ជាដំណើរដោយស្រួលមិនមានលំបាកអ្វីឡើយ ព្រោះផ្លូវដែលទៅអង្គរនោះ មាន ២ យ៉ាងគឺ

១ ផ្លូវគោកទៅដោយរថយន្តគឺរនេះឡាន ទៅនោះបំនួន ៩ ឬ ១០ ម៉ោងក៏ដល់ទៅសៀមរាប ផ្លូវគោកនេះទៅបានគ្រប់រដូវ ។

២ ផ្លូវទឹកទៅដោយកប៉ាល់ ទៅនោះបំនួន ២២ ឬ ២៣ ម៉ោងក៏ដល់ទៅកន្លែងសំរាបចុះពីកប៉ាល់ ហើយត្រូវទៅដោយរថយន្តតាមផ្លូវបំនួន ១៤ គីឡូម៉ែត្រ ក៏ដល់ទៅសៀមរាប ផ្លូវទឹកនេះ ទៅបានតែក្នុងរដូវទឹកឡើង តាំងពីខែអាសាធដរាបដល់ខែមាឃ ។

កាលបើដល់ទៅទីប៉ុស្តិ៍សៀមរាប នៅទីសៀមរាបនោះ មានផ្ទះហោតិលរបស់អ្នកស្រុកអ្ញ គឺផ្ទះសំរាបជួលសំណាក់អាស្រ័យ និងសំរាបលក់អស់ទាំងអាហារភោជន បណ្តាជាតិខ្មែរ

សៀម លាវ គឺឯងយួន បិណា ដែលទៅពីស្រុកធ្លាយ ជើម្បីនឹងទៅមើលអង្គរ អាចនឹងចូលទៅជួលសំណាក់អាស្រ័យនៅផ្ទះហោតិលនោះបាន ។


ម្យ៉ាងទៀតនៅសៀមរាបនោះមានអ្នកនាំផ្លូវ ដែលរាជការបានតាំងទុកសំរាបនឹងនាំអ្នកដំណើរទៅមើលទីអង្គរ អ្នកនោះបេះរឿងអង្គរហើយនឹងរឿងពង្សាវតារខ្មែរ អាចបង្ហាល់ដល់អ្នកដំណើរទាំងពួង ឲ្យដឹងរឿងរ៉ាវក្នុងទីអង្គរ ដោយសព្វគ្រប់បានដោយភាសាខ្មែរនឹងភាសាសៀម ។

បើអស់អ្នកដំណើរ ត្រូវការនឹងឲ្យអ្នកនាំផ្លូវនោះ ជូនទៅមើលអង្គរ ក៏ត្រូវទៅជំរាបលោក ឡឺវេស៊ុដឹងត៍សៀមរាប លោក ឡឺវេស៊ុដឹងត៍ នឹងចាត់ឲ្យអ្នកនាំផ្លូវនោះជូនទៅ ១រំពេច ដោយឥតថ្លៃ ។

ដែលនឹងទៅពីសៀមរាប បំពោះទៅមើលទីអង្គរនោះ បើទៅដោយរបិយន្ត ត្រូវទៅតាមផ្លូវប៉ុល់បំនួន ៦២០០ ម៉ែត្រ ក៏នឹងដល់ទៅផ្លូវឬ ដែលបែកត្រង់ជាប់ទៅប្រាសាទអង្គរវត្ត ត្រូវ

បញ្ឈប់របស់ខ្លួនទៅទីនោះ ហើយបូរដើរទៅមើលប្រាសាទអង្គរវត្ត រួចហើយបូរត្រឡប់ទៅមើលប្រាសាទដទៃ ។ តាមសេចក្តីត្រូវការ ប៉ុះ ។

បើអស់អ្នកដំណើរមិនមានពេលប្រើន គួរទៅមើលតែអង្គរវត្តបាយ័ន ទីព្រះលានស្តេច ព្រះខ័នធំឯនាគព័ន្ធ ហើយបូរត្រឡប់មកវិញដោយរបស់ខ្លួនតាមផ្លូវរាងធំ បំពោះទៅសៀមរាប បើមានពេលប្រើន ក៏បូរអញ្ជើញទៅមើលប្រាសាទដទៃ ។ តាមសេចក្តីត្រូវការ ———



អង្គរវត្ត (នគរវត្ត)

អង្គរវត្តនេះ គេធ្វើឧទ្ទិសប្បាយជំលសាសនាព្រាហ្មណ៍ គឺប្បាយជំលព្រះវិស្ណុ អង្គរវត្តនោះ គេមើលពីចម្ងាយទៅឃើញកំពូលមានសណ្ឋានដូចភ្នំសុមេរុ នៅជុំវិញអង្គរវត្តមានស្រះ[1] មានទឹកជក់នៅជានិច្ច ស្រះនោះគេរៀបច្បាំជាថ្នាក់ៗ ដូចជាជណ្តើរសម្រាបបុះទៅក្នុងស្រះ តរពីស្រះទៅមានកំផែងព័ទ្ធជុំវិញ នៅកំផែងនោះមានទ្វារសំរាបចេញចូល គ្រប់ទិសទាំង ៤ តែទ្វារធំនៅជាខាងឯលិច មានផ្លូវប្តល់ខាងក្រៅឆ្លងកាត់ស្រះទៅរហូតជំលទៅទ្វារធំនោះ នៅកំផែងទិសខាងលិច គេធ្វើមានសណ្ឋានជារោងថែវ នៅរោងថែវនោះមានទ្វារ ៥ គឺទ្វារ ៣ នៅកណ្តាល ទ្វារ ២ នៅទីបំផុតរោងថែវ ឯទ្វារ ៣ កណ្តាលជាទ្វារចេញចូលបាន តែទំងបររទែះសេះជំរី ចេញចូលមិនបាន ព្រោះទ្វារទាំង ៣ នោះជាទីមានផ្ទៃខ្ពស់ សុទ្ធតែមានជណ្តើរឡើងទៅ

---

(១) អ្នកស្រុកអង្គរនោះ គេហៅសព្វថ្ងៃនេះថា ទីសិន ពាក្យនេះប្រែហែលជាក្លាយមកពីពាក្យជាលីថា សិន្ធុ ទេដឹង ។


ឯទ្វារ ២ នៅទីបំផុតរោងថែរនោះ នឹងបររទេះសេះជិរ ចេញចូលបាន ព្រោះទ្វារនោះមានផ្ទៃខាងក្រោមរាបស្មើនឹងផែនដី ឯត្រង់កន្លែងទ្វារកណ្តាលទាំង ៣ សុទ្ធតែមានកំពូលខ្ពស់ទ្បើងជាគួរប្រសាទតែត្រង់ទ្វារ ១ កណ្តាលនោះមានកំពូលខ្ពស់ជាងកំពូលទ្វារទាំង ២ ដែលនៅសងខាង សព្វថ្ងៃនេះគេដើរចេញចូលតែតាមទ្វារធំកណ្តាល ១ ព្រោះទ្វារនោះមានជណ្តើរបុះទ្បើងបំត្រង់ផ្លូវឬដែលជាប់ពីផ្លូវឬល់ខាងក្រៅទៅ ឯទ្វារ ២ សងខាងនោះគេពុំសូវចេញចូលទេ ព្រោះជណ្តើរបុះទ្បើងខុសពីផ្លូវនោះ ហើយមានទាំងរូបព្រះនារាយណ៍មួយ ៗ នៅត្រង់កណ្តាលទ្វារទាំង ២ នោះផង ។ រោងថែរនោះមានបង្អួចជាច្រើន តែឥតមានសន្លឹកបើកចេញចូលទេ មានតែបម្រាំងជើងទៀនតៅត្រង់រង្វង់បង្អួចទាំងនោះ ឃើញមានក្បាច់បម្លាក់ជាច្រើនតែក្បាច់បម្លាក់នោះរាក់ៗស្តើងៗ អ្នកខ្លះយល់ថាក្បាច់ទាំងនោះ មានទំនងភាពប្រហែលដូចជាក្បាច់របស់បិណា នៅទីរោងថែរនោះមានក្បាច់បម្លាក់ នឹងរូបបម្លាក់ជាច្រើន តែរូបបម្លាក់ទាំងនោះ សុទ្ធតែជារូបបំណែកខាងសាសនាព្រាហ្មណ៍ ។

កំផែងតរពីរោងបៃវគោះទៅ គេធ្វើដោយឫបាយក្រៀមជុំវិញ រៀរលែងតែត្រង់កន្លែងទ្វារទាំង ៣ ទិស គឺខាងកើត ខាងត្បូង ខាងជើង គេធ្វើដោយឫពណ៌ប្រផេះ នៅត្រង់ទ្វារទាំង ៣ នោះក៏សុទ្ធតែមានជំហូលខ្ពស់បន្តិច ៗ តែមិនមានកំពូលខ្ពស់ជាតួប្រាសាទដូចជាទ្វារធំខាងឯលិចទេ ។

លុះដល់ចេញផុតពីរោងបៃវតាមទ្វារខាងឯលិចបុះជណ្តើរ ៤-៥ កាំទៅ ត្រូវដើរទៅតាមផ្លូវឫ ៗ នោះ មានផ្ទៃខ្ពស់ពីផែនដី ហើយមានរូបនាគឫជាប្រកាន់ដៃទាំងសងខាងផ្លូវ ដើរបន្តិចទៅទៀតឃើញបណ្ណាល័យ ២ នៅសងខាងផ្លូវ តែបណ្ណាល័យនោះសព្វថ្ងៃនេះបាក់បែកអស់ទៅហើយ ក្បាច់បម្លាក់នៅបណ្ណាល័យនោះក៏របេះរបកទឹងរលុបអស់ជាច្រើន លុះដើរបន្តិចទៅទៀតទឹងឃើញស្រះ ២ តូច ៗ នៅសងខាងផ្លូវនោះ ដើរតរពីនោះតែបន្តិចទៅ ទឹងដល់ទៅទីលានដី ដែលជាទីទ្រប្រាសាទអង្គរវត្ត ផ្លូវឫទឹងទីលានដី នោះមានផ្ទៃស្មើគ្នា ទីលានដីនោះមានរូបនាគឫជាប្រកាន់ដៃជុំវិញ ហើយមានជណ្តើរបុះទៅគ្រប់ទិស ។

ប្រាសាទអង្គរវត្តនោះមានជាន់ ៣

ជាន់ទី ១ — ជាន់ទី ១ គេធ្វើជារោងថែវមានដំបូលព័ទ្ធជុំវិញនៅ
ត្រង់ជ្រុងរោងថែវទាំង ៤ ទិស មានកំពូលខ្ពស់បន្តិចឡើង មាន
សណ្ឋានដូចជាប៉ម នៅមុខទ្វារខាងឯលិច មានទីធ្លៃឬជាយ៉ាតត
ជម្បូលជាប់តរពីរោងថែវនោះមក មានជណ្តើរឡើងពីខាងលិច
ខាងឯជើង ខាងឯត្បូង នៅសងខាងទីយ៉ានោះមានរូបនាគឬជា
ប្រកាន់ដៃ លុះដើរតាមទីយ៉ាឬនោះបន្តិចទៅ ក៏ចូលទៅក្នុងទ្វារ
រោងថែវ ត្រង់កន្លែងទ្វារនោះ គេធ្វើជាតួប្រាសាទបន្តិចខាងលើ
ហើយមានដំបូលយ៉ាចេញមកខាងឯលិច នៅហោជាងដំបូលយ៉ា
នោះ មានក្បាច់បម្លាក់ខាងសាសនាព្រាហ្មណ៍ លុះដើរចូលទៅ
ជិលកណ្តាលរោងថែវ ហើយដើរបែរទៅតាមរោងថែវខាងស្តាំនឹង
ឃើញជញ្ជាំងនៅជាខាងឆ្វេង នៅទីជញ្ជាំងនោះឃើញមានរូប
បម្លាក់រមែបជារឿងរ៉ាវ នឹងសិលាចារឹក គឺអក្សរដែលឆ្លាក់នឹងឬ
ជាច្រើន ដោយជុំវិញជាបមកជិលជញ្ជាំងទល់នឹងទ្វារខាងលិច
ឯរឿងរ៉ាវនឹងសិលាចារឹកនោះ ខ្ញុំបាសបក្តីដែលពណ៌នាដោយ
សង្ខេបតរទៅនេះ ។



ប្រាសាទអង្គរវត្តកាលមិនទាន់កាប់ឆ្ការព្រៃ

១ នៅជញ្ជាំងខាងលិចប៉ែកខាងស្តាំ ឃើញរឿងមហាភារត ត្រង់បម្បាំងបណ្ដាវនឹងកោរវ (រឿងនេះជារឿងបម្បាំងធំ ១ ក្នុងរឿងព្រេងនៅស្រុកឥណ្ឌៀ រឿងនេះមានតែក្នុងអក្សរសំស្ក្រឹតឯក្នុងអក្សរខ្មែរមិនមាន) ។

២ នៅជ្រុងថែរទិសនិរតី ត្រង់ជ្រុងនេះបែកជា ៤ ជាន គឺជាន ១ ខាងជើង ១ ខាងត្បូង ១ ខាងលិច ១ ខាងកើត ត្រង់ជាន ខាងជើងជញ្ជាំងខាងកើត ឃើញរឿងកិស្នាដែលកើតពីវិស្ណុជាទេវតាឃ្វាលគោ កាលទ្រុំគោវធន៍ ដើម្បីនឹងបាំងទឹកភ្លៀងកុំឲ្យទទឹកអស់ទាំងហ្វូងគោ ជញ្ជាំងខាងលិចត្រង់លើបង្អួច ឃើញរឿងក្អូរសមុទ្រទឹកដោះ ត្រង់ទេវតានឹងអសុរទាញនាគ ត្រង់ជាន ខាងត្បូងជញ្ជាំងខាងកើតភាគខាងលើ ឃើញរឿងរាមាយណ ត្រង់ពាលីនឹងសុគ្រីពប្បាំងគ្នា ភាគខាងក្រោមឃើញពាលីស្លាប់ ជញ្ជាំងខាងលិចភាគខាងលើ ឃើញរូបព្រះឥស្សរដំណែងខ្លួនជាឥសីប្រដាប់ដោយផ្កាំ ភាគខាងក្រោមឃើញទេវតាពេជ្ឈៈ កាមជាអ្នកបណ្ដាលឲ្យកើតទ្បើងនៅសេចក្ដីដម្រែក កំពុងតែបាញ់ដម្រង់ទៅព្រះឥស្សរ ។ ក៏ក្រឡេកមើលមកទេវតាឈ្មោះ កាម

ដោយភ្នែកដែលមានតៅត្រង់ថ្ងាស ទេវតាឈ្មោះ កាម ក៏ឆេះ
រលាយទៅជាផេះ ត្រង់ជាន១ខាងលិចជញ្ជាំងខាងត្បូងឃើញរូប
ព្រះឥស្សរអង្គុយលើភ្នំ ហើយឃើញរាពណ៌មានដៃ ២០ ក្បាល
១០ កំពុងតែធ្វើភ្នំឲ្យរំជួលដោយសេចក្តីឈ្នានីសដល់ព្រះឥស្សរ
ជញ្ជាំងខាងជើងឃើញ រឿងមិនប្រាកដជារឿងអ្វី ត្រង់ជាន១ខាង
កើត តៅទីខាងលើទ្វារឃើញរូបព្រះនារាយណ៍មានដៃ ៤ ហើយ
ឃើញរូបអ្នកដែលយកវរបស់ទៅប្លួជា ។

៣ តៅជញ្ជាំងខាងត្បូងបែកខាងឆ្វេង ឃើញរឿងពង្សាវ-
តារខ្មែរនឹងសិលាចារឹកប្រាប់ពីរឿងដែលមានតៅទីនោះ សិលា
ចារឹក ១ ប្រាប់ថាមនុស្ស ដែលជាមេជានាយនឹងជាបណ្ឌិតទាំង
ឡាយយកដង្វាយទៅថ្វាយស្តេច តរពីនោះបន្តិចទៅឃើញសិ-
លាចារឹក ១ ទៀត ប្រាប់ថាស្តេចបរមវិស្ណុលោកនៅលើភ្នំសិរិបទ
គ្រាសបង្គាប់ឲ្យប្រម៉ូលពួកកងទ័ព្យ តរពីនោះទៅទៀតឃើញរូប
ជិះលើជំរីជាច្រើន រូបទាំងនោះសុទ្ធតែជារូបមន្ត្រី កាត់សក់មាន
ភាពទំនងដូចជាសក់ដែលខ្មែរកាត់សព្វថ្ងៃនេះ ហើយឃើញមាន
សិលាចារឹកជាច្រើន ប្រាប់ឈ្មោះមន្ត្រីទាំងនោះ ឃើញរូប ១ ទៀត

ឈរលើជំរំរូបនោះគឺជារូបស្តេច ព្រោះឃើញសិលាចារឹកនៅជិត
រូបនោះប្រាប់ថានេះជាស្តេច ឈ្មោះស្រីជយេន្ទ្រវរ្ម័ន នៅក្នុងពួក
កងទ័ព្យទាំងនោះឃើញមានរូបព្រាហ្មណ៍ជាច្រើន សុទ្ធតែមាន
ផ្ទៃងសក់ព័ទ្ធឆ្អាក់ដោយអង្កាំ ឃើញរូបព្រាហ្មណ៍ ១ ជិះលើអង្រឹង
រូបព្រាហ្មណ៍នោះប្រហែលជាមានសក្តិធំជាងគេ ព្រាហ្មណ៍ទាំង
នោះសុទ្ធតែកាន់គ្រឿងប្រដាប់របស់ពួកព្រាហ្មណ៍ ហើយឃើញ
រូបព្រាហ្មណ៍ខ្លះសែងរោងភ្លើង តរពីនោះទៅទៀតឃើញមានស-
លាចារឹក ១ ទៀតប្រាប់ថានេះជាស្បាមកុត ។

៤ នៅជញ្ជាំងខាងត្បូងប៉ែកខាងស្តាំ ឃើញបម្លាក់រឿង
នរកនឹងស្ថានសួគ៌ ហើយនឹងសិលាចារឹកជាច្រើន សិលាចារឹក ១
ប្រាប់ថានេះជាផ្លូវខាងលើគឺស្ថានសួគ៌ សិលាចារឹក ១ ទៀតប្រាប
ថានេះជាផ្លូវខាងក្រោមគឺនរក រូបបម្លាក់ត្រង់នេះ មាន ៣ ផ្នែក
គឺផ្នែកខាងលើនិយាយពីស្ថានសួគ៌ ផ្នែកខាងក្រោមនិយាយពី
ស្ថាននរក ផ្នែកកណ្តាលឃើញសុទ្ធតែរូបគ្រុឌ ។

កាលបើមើលត្រង់ផ្នែកខាងក្រោម ដើរតរទៅនឹងឃើញ
សិលាចារឹក ១ ប្រាប់ថានេះជាព្រះយម ឃើញរូបព្រះយមនោះ

មានដៃ ១៨ ហើយជិះលើគោ តរពីនោះទៅឃើញសិលាចារឹក ១ ទៀតប្រាប់ថា នេះជាព្រះធម៌ជាធំខាងការជំនុំជិះ នៅជិតនោះ ឃើញរូបចិត្តគុប្តជាក្រឡាបញ្ជីនៃព្រះយម កំពុងតែលើកដំបងបង្អុលទៅអស់ពួកសត្វនរក តែសិលាចារឹកនោះឥឡូវនេះរលប់មើលមិនច្បាស់ តរពីនោះទៅទៀតឃើញមានសិលាចារឹក ជាច្រើនប្រាប់ឈ្មោះស្ថាននរកផ្សេង ៗ គឺឯងទោសរបស់អ្នក ដែលទៅនរកនោះដូចសិលាចារឹក ដែលបានតាំមកពោលខ្លះក្នុងខាងក្រោយនេះ ។

សិលាចារឹកប្រាប់ថានរកឈ្មោះ អវីចិ សំរាបអ្នកដែលមានទ្រព្យសម្បត្តិ ហើយប្រព្រឹត្តធ្វើតែអំពើបាប ។

សិលាចារឹកប្រាប់ថា នរកឈ្មោះក្រិមិនិចយ សំរាបអ្នកដែលប្រមាទមើលងាយ ឬតេះដៀលដល់ទេវតា ដល់ភ្លើង ដ៏ប្រសើរដល់គ្រូអាចារ្យ ដល់ពួកព្រាហ្មណ៍ ឬតេះដៀលមើលងាយដល់ព្រះធម៌ ដល់អ្នកបំរើព្រះឥសូរ ឬដល់អ្នកដែលគួរគោរពមានមាតាបិតាជាដើម ។

សិលាចារឹកប្រាប់ថា នរកឈ្មោះវៃតរណីទនី សំរាប់អ្នកដែលធ្វើបាបគេ លួចគេ ។

តរទៅឃើញមានសិលាចារឹក ១ ទៀត តែមិនច្បាស់ត្រង់ឈ្មោះនរក ឃើញតែសេចក្តីថា សំរាប់អ្នកដែលនិយាយមិនពិត ឬមនុស្សដែលធ្វើជាបន្ទាល់ខុស ។

សិលាចារឹកប្រាប់ថា នរកឈ្មោះយុគ្មបវិត (យុគ្មបត៌ត) សំរាប់មនុស្សដែលកាចព្រហើនដែលកាប់សំឡាប់គេ ។

សិលាចារឹកប្រាប់ថា នរកឈ្មោះនិរុច្ឆាស សំរាប់មនុស្សដែលកាបសាហ៍ស កាប់សំឡាប់អស់ទាំងស្ត្រី អស់ទាំងក្មេងតូច ។ ។

សិលាចារឹកប្រាប់ថា នរកឈ្មោះទុច្ឆាស សំរាប់អ្នកដែលប្រព្រឹត្តអំពើទុច្ចរិត នឹងអ្នកដែលនិយាយដើមគេ នឹងអ្នកដែលបរិភោគនូវសាច់ជាអកប្បិយ គឺសាច់មិនគួរបរិភោគតាមលទ្ធិក្នុងសាសនាព្រាហ្មណ៍ ។

សិលាចារឹកប្រាប់ថា នរកឈ្មោះទ្រវិត្តិបុ សំរាប់អ្នកដែល

ធ្វើនូវអំពើអាក្រក់ដល់អ្នកដទៃ គឺឯអ្នកដែលកំហែងយកដីយកផ្ទះយកទីលំនៅអ្នកដទៃ ។

សិលាចារឹកប្រាប់ថា នរកឈ្មោះតប្តលាក្សាមយ សំរាប់អ្នកដែលដុតបំផ្លាញរបស់អ្នកដទៃ មានដុតផ្ទះជាដើម គឺឯអ្នកដែលទ្បាំបំពុលដល់អ្នកដទៃ ។

សិលាចារឹកប្រាប់ថា នរកឈ្មោះអស្តិភង្គ សំរាប់អ្នកដែលធ្វើបង្កូចបំផ្លាញរបស់អ្នកដទៃ មានសូនប្បាគឺឯផ្ទះជាដើម ។

សិលាចារឹកប្រាប់ថា នរកឈ្មោះក្រកច្ឆេទ សំរាប់អ្នកដែលល្មោភស៊ី ។

សិលាចារឹកប្រាប់ថា នរកឈ្មោះបូយប្បណាំហ្រែទ សំរាប់អ្នកដែលលួចស្រា លួចប្រពន្ធគេ ។

សិលាចារឹកប្រាប់ថា នរកឈ្មោះអស្រិក្ឃ្លណាំហ្រែទ សំរាប់អ្នកដែលលួចសាប់ លួចប្រពន្ធអ្នកដទៃ គឺឯប្រពន្ធអ្នកចេះដឹងគឺអ្នកប្រាជ្ញ ។

សិលាចារឹកប្រាប់ថា នរកឈ្មោះមេទោហ្រែទ សំរាប់ស្ត្រីដែលមានសេចក្តីទុច្ចរិត ។

ឃើញសំលាចារឹក១ទៀតរលប់មើលមិនច្បាស់តែនៅជិត សំលាចារឹកនោះឃើញមនុស្សមានពោះធំគេកំពុងតែវាយ ។

សំលាចារឹកប្រាបថា នរកឈ្មោះ តិក្ខាយស្ពន្ធ សំរាបអ្នកដែលលួចស្រែវលួចអង្ករគេ ។

តរពីនោះទៅទៀតឃើញមានសំលាចារឹកជាច្រើនន័យាយពីនរកសំរាបអ្នកដែលកាប់ដើមឈើអ្នកលួចដំរីអ្នកដែលលួចផ្កាក្នុងសួនច្បាព្រះឥស្សរ ។ ល ។ ល ។ បើរួបរួមស្ថាននរកនឹងស្ថានសួគ៌ទាំងអស់ ស្ថាននរកមាន ៣២ ស្ថានសួគ៌មាន ៣៧ ។


៥ នៅជញ្ជាំងខាងកើត ប៉ែកខាងឆ្វេង ឃើញរឿងរាមាយណត្រង់កណ្តាន័យាយពីក្សត្រសមុទ្ទទឹកដោះក្នុងរឿងនេះឃើញរូបនាគធំវែងស្ទើរតែនឹងផ្ទុតជញ្ជាំងប្រវែង ៤៩ ម៉ែត្រហើយឃើញទេវតានឹងអសុរជាច្រើនទាញនាគនោះ ទេវតាទាញខាងក្បាលអសុរទាញខាងកន្ទុយនៅត្រង់កណ្តាលឃើញរូបព្រះនារាយណ៍មានដៃ ៤ នៅផ្ងារប់នឹងភ្នំមន្ទរ ។ នោះស្ថិតនៅលើអណ្តើក ។

៦ នៅជញ្ជាំងខាងកើតប៉ែកខាងស្តាំ ឃើញរឿងចម្បាំងនៃទេវតានឹងអសុរ នៅកណ្តាលចម្បាំងនោះ ឃើញរូបវិស្ណុជិះលើគ្រុឌ ។

៧ នៅជញ្ជាំងខាងជើងបែរខាងឆ្វេង ឃើញរឿងមហាភារត ។

៨ នៅជញ្ជាំងខាងជើងបែរខាងស្តាំ ឃើញកុវេរជិះលើស្មាយក្ស ទេវតាឈ្មោះស្កន្ធជិះលើក្អែក ព្រះឥន្ទ្រជិះលើដំរីឈ្មោះវណ វិស្ណុជិះលើគ្រុឌ យមជិះលើរថទឹមដោយគោ សិវ ព្រហ្មជិះលើហង្ស សូរ្យនៅក្នុងមណ្ឌល វរុណជិះលើនាគ ។

៩ នៅជ្រុងថែរទិសពាយព្យ ត្រង់ជ្រុងនេះបែកជា ៤ ជាន គឺជាន ១ ខាងកើត ១ ខាងលិច ១ ខាងជើង ១ ខាងត្បូង ត្រង់ជានខាងកើតជញ្ជាំងខាងត្បូង ឃើញរូបវិស្ណុជិះលើគ្រុឌ ឃើញវិស្ណុកាន់មន្ទរដើម្បីទំងក្អរទឹកសមុទ្រ ជញ្ជាំងខាងជើងភាគខាងលើ ឃើញព្រះនារាយណ៍ជិះលើនាគ ភាគខាងក្រោមឃើញទេវតាទាំង ៩ ខាងសាសនាព្រាហ្មណ៍ គឺសូរ្យជិះលើរថ កុវេរជាទេវតាខាងភោគសម្បទ ជិះលើយក្ស ព្រហ្មជិះលើហង្ស ស្កន្ធជិះលើក្អែក ទេវតា ១ ទៀតជិះលើសេះ ព្រះឥន្ទ្រជិះលើដំរី ព្រះយមជិះលើគោ សិវជិះលើគោឧសភ ទេវតា ១ ទៀតជិះលើសីហ ត្រង់ជានខាងលិចជញ្ជាំងខាងត្បូង ឃើញរឿងរាមាយណ ត្រង់



ប្រាសាទអង្គរវត្តវែលកាប់ផ្តាច្រៃហើយ

សេចក្តីកាលហណុមាន យកបិញ្ជៀនទៅប្លុយនាងសិតា នៅ
កោះលង្កា ជញ្ជាំងខាងជើងឃើញរឿងមឹនប្រាកដ ត្រង់ជាន
ខាងជើងជញ្ជាំងខាងលិប ឃើញរឿងរាមាយណ កាលព្រះរាម
ឱ្យនាងសិតាបួលភ្លើង ជញ្ជាំងខាងកើតឃើញរឿងមឹនប្រាកដ
ត្រង់ជានខាងត្បូងជញ្ជាំងខាងកើត ឃើញរឿងរាមាយណាកាល
ព្រះរាមប្លែងសរប្រទ្បងដើម្បីនឹងយកនាងសិតា ជញ្ជាំងខាងលិប
ឃើញរឿងមឹនប្រាកដ ។

១០ នៅជញ្ជាំងខាងលិប ប៉ែកខាងឆ្វេង ឃើញរឿង
បម្បាំងនៃព្រះរាមនឹងរាពណ៍ ។

កាលបើមើលរូបបម្លាក់រម្លេចនិយាយពីរឿងរ៉ាវ នៅជញ្ជាំង
រោងថែរជាន់ទី ១ សព្វគ្រប់ហើយ ត្រូវទៅតាមផ្លូវទ្វារខាងលិប
ត្រង់ចំពោះទៅជណ្តើរដែលសំរាបឡើងទៅកាន់រោងថែរក្នុងជាន
ទី ២ ។

ជាន់ទី ២ — ជាន់ទី ២ មានទំហំតូចជាងជាន់ទី ១ តែខ្ពស់ជាង
ហើយមានរោងថែរព័ទ្ធជុំវិញ បំណែកទិសខាងលិប ត្រង់ចន្លោះ
រោងថែរជាន់ទី ១ នឹងរោងថែរជាន់ទី ២ មានជាងថែរប្រទាក់គ្នា

ខ្ញាត់ខ្វែងជាក្រឡាឈើត្រង់ គឺរោងថែរនោះមាន ៣ ជួ តរជាប់ពី
រោងថែរជាន់ទី ១ ទៅរោងថែរជាន់ទី ២ កាលបើទៅពីរោងថែរ
ជាន់ទី ១ តាមទ្វារធំកណ្តាល គឺឯទៅតាមជណ្តើរកណ្តាលបំនួន
៦—៧ កាំទៅកាន់រោងថែរកណ្តាល បើទៅតាមទ្វារទាំងសងខាង
គឺឯទៀងតាមជណ្តើរទាំងសងខាង ទៅកាន់រោងថែរទាំងសង-
ខាង មានរោងថែរ ១ ទៀតកាត់ទទឹងបំពាក់កណ្តាល ជាប់ពីរោង
ថែរខាងត្បូងទៅរោងថែរខាងជើង ក្នុងបន្ទោះទាំង ៤ នៃរោងថែរ
នោះមានស្រះតូចៗបួន ។ ក្នុងរោងថែរខាងត្បូង ឃើញមានព្រះ
ពុទ្ធរូបជាប្រើនព្រះអង្គ ជាព្រះពុទ្ធរូបសាងតាមបែបខាងមហា-
យានខ្លះ ហីនយានខ្លះ តែដៃលគេយកមកជំកល់ក្នុងទីនោះ ក្នុង
កាលផ្សេងៗគ្នា ខ្លះយកមកមុនខ្លះយកមកក្រោយ កាលបើចេញ
ពីទ្វាររោងថែរខាងជើងគឺឯខាងត្បូងទៅគឺឯឃើញបណ្តាល់យ ២
នៅលើទីផ្ទៃខាងក្រោមដៃលទ្រជាន់ទី ២ ដៃលគឺឯទៀងទៅកាន់
រោងថែរជាន់ទី ២ នោះមានជណ្តើរ ១៤ សំរាបទៀងទៅ គឺឯទៀង
ទៅតាមជណ្តើរណា ១ ក៏បាន តែបើទៅតាមផ្លូវខាងលិច ត្រូវដើរ
ទៅតាមរោងថែរកណ្តាល ហើយទៀងទៅតាមជណ្តើរកណ្តាល

បំនួន ១៧ – ១៨ កាំ ក៍ជាល់ទៅលើទីធ្លៃរោងថៃវជាន់ទី ២ នៅ
ក្នុងរោងថៃវនេះ ឃើញមានរូបព្រះនារាយណ៍មានដៃ ៤ នៅប្រៃប
ផ្លូវខាងលិច ឃើញរូបព្រះនារាយណ៍ ២ ទៀត នៅត្រង់ទ្វាររោង
ថៃវខាងត្បូង ព្រះនារាយណ៍នោះមានដៃ ៤ ត្រង់ពាក់កណ្តាល
ខ្នងខាងក្រោមឃើញទ្រង់ជារូបអណ្តើក ហើយឃើញមានទាំង
ព្រះពុទ្ធរូបជាប្រើនអង្គ ព្រះពុទ្ធរូបទាំងនោះ គេទើបនឹងយកមក
ដំកល់ទុកក្នុងកាលជាខាងក្រោយទេ ។

កាលបើបូលផុតពីជាន់ទី ២ តាមទ្វាររោងថៃវខាងលិច ក៍
ជាល់ទៅទីធ្លៃខាងក្រោមដែលទ្រជាន់ទី ៣ ។

ជាន់ទី ៣ – នៅធ្លៃខាងក្រោមជាន់ទី ៣ មានផ្លូវប្តូចជាស្តាន
តរជាប់ពីថៃវជាន់ទី ២ មក ផ្លូវប្តូនោះ ជាប់ទៅនឹងជណ្តើរខ្ពស់
ដែលនឹងឡើងទៅកាន់ជាន់ទី ៣ ហើយមានផ្លូវ ១ ទៀតកាត់ពាក់
កណ្តាលផ្លូវនោះទៅខាងជើងនឹងខាងត្បូង ជាប់ទៅនឹងប្រាសាទ
តូចៗ នៅខាងជើង ១ ខាងត្បូង ១ ប្រាសាទទាំង ២ នោះ ឥឡូវ
នេះបាក់បែកអស់ហើយ ។

ជាន់ទី ៣ នេះមានទំហំតូចជាងជាន់ទី ២ តែខ្ពស់ជាង

ជាន់ទី ២ ហើយមានជណ្តើរសំរាបឡើងទៅ ១២ គឺជណ្តើរ ៣ ខាងលិប ៣ ខាងកើត ៣ ខាងជើង ៣ ខាងត្បូង បើឡើងទៅលើជាន់ទី ៣ ត្រូវឡើងតាមជណ្តើរកណ្តាលខាងលិប ព្រោះជណ្តើរនោះមឹនស្មើរចោតពេក ឡើងទៅបំនួន ៣៥ កាំ ក៏ដល់ទៅខាងលើជាន់ទី ៣ នៅលើជាន់ទី ៣ នោះមានប្រាសាទ ១ នៅត្រង់កណ្តាលមានរោងថែរព័ទ្ធជុំវិញ ហើយមានរោងថែរជាប់ពីថែរខាងលិប ខាងកើត ខាងត្បូង ខាងជើង តរទៅប្រជុំភ្ជាប់គ្នានឹងប្រាសាទកណ្តាល ហើយមានប្រាសាទមួយៗនៅគ្រប់ជ្រុងរោងថែរទាំង ៤ តែប្រាសាទជ្រុងទាំង ៤ នោះ តូចនឹងទាបជាងប្រាសាទកណ្តាល កំពូលប្រាសាទទាំង ៥ នោះហើយ ដែលយើងបានពោលខាងដើម ថាមានសណ្ឋានដូចភ្នំព្រះសុមេរុ ក្នុងបន្លោះទាំង ៤ នៃរោងថែរនោះមានស្រះតូចៗបួន កាលចូលទៅដល់ប្រាសាទកណ្តាល នឹងឃើញមានព្រះពុទ្ធរូបឈរ ១ ព្រះអង្គ មានរូបអគ្គសាវ័កទាំង ២ កំពុងនមស្សការ ជាព្រះរូបគេធ្លាក់បន្តុំនៅនឹងជើងឬ្ម នៅទីខាងមុខព្រះពុទ្ធរូបឈរនោះ ឃើញមានព្រះពុទ្ធរូបជាប្រើនព្រះអង្គ ល្អខ្លះបាក់បែកខ្លះ ដែលឃើញមានយ៉ាង

នេះតែ ៣ ទិសទេ គឺខាងលិប ខាងកើត ខាងជើង ឯខាងត្បូងមិន
ឃើញមានអ្វីឃើញតែបន្លោះរង្វង់ទ្វារទេ ។

យើងបូលបិត្តជាព្រះពុទ្ធរូប ដែលគេឆ្លាក់ភ្ជាប់នឹងផែនប្ញ
ក្នុងប្រាសាទកណ្តាលនោះគេទើបនឹងធ្វើក្នុងកាលជាខាងក្រោយ
មិនមែនគេធ្វើដូចនោះតាំងពីក្នុងជាន់ធ្វើអង្គរនោះទេ កាលពីដើម
គេធ្វើរូបព្រះវិស្ណុដំកល់ទុកក្នុងប្រាសាទកណ្តាលនោះ ព្រោះស្តេច
ដែលកសាងទីអង្គរវត្តនោះ ជាអ្នកកាន់សាសនាព្រាហ្មណ៍ តែ
ដល់មកខាងក្រោយ មានពួកអ្នកកាន់ព្រះពុទ្ធសាសនាខាងហីន-
យានមកនៅគ្រប់គ្រងរក្សាទីនោះ ក៏លើកយករូបព្រះវិស្ណុនោះ
បេញ ហើយយកប្ញទៅដាក់ស្ទះត្រង់កន្លែងទ្វារទាំង ៤ ទិស ទើប
ឆ្លាក់ព្រះពុទ្ធរូបឈរនឹងផែនប្ញនោះគ្រប់ទ្វារទាំង ៤ ទិស ឯទិស
ខាងត្បូងសព្វថ្ងៃនេះមិនឃើញមាន ព្រោះគេទើបនឹងរើបេញ
ខាងក្រោយទេ ។

ប្រាសាទអង្គរវត្តនោះ កាលណាបើឡើងទៅដល់ជាន់ខាង
លើហើយ ក្រឡេកមើលទៅខាងក្រោមឃើញល្អណាស់ តែបើ
មើលក្នុងពេលដែលព្រះអាទិត្យរៀបនឹងអស្តង្គត ក៏រីងរិតតែ

ឃើញល្អគួរតែចង់ឲ្យមើលណាស់ព្រោះក្រែងក្រឡេកមើលតាមឲ្យៗទៅ ក៏បណ្តាលឲ្យកើតឡើងនូវសេចក្តីស្រងូតស្រងាត់ក្នុងចិត្ត ។

លុះដល់ត្រឡប់បុះមកវិញ ហើយក្រែងក្រឡេកមើលក្បាច់បម្លាក់នៅជញ្ជាំង នៅសសរ នៅក្លោងទ្វារ ហើយនឹងបង្ខំចិត្តតាមផ្លូវដែលដើរបុះមក ក៏នឹងឃើញក្បាច់បម្លាក់ទាំងនោះល្អណាស់គួរឲ្យចង់មើលគួរឲ្យស្ងើចក្នុងចិត្តដោយក្រៃលែង (សូមឲ្យអស់លោកអ្នកដែលទៅមើលអង្គរ កាលបើត្រឡប់បុះមកវិញ សូមឲ្យក្រែងក្រឡេកមើលទៅខាងក្រោយវិញកុំខានឡើយ) ។

លុះបុះមកដល់ជាន់ទី ១ ត្រង់ទីយ៉ាងនៅមុខទ្វារខាងលិចនឹងបានឃើញនូវវត្តលោកសំឃគណមហានិកាយ ២ វត្ត វត្ត ១ នៅជាខាងជើង វត្ត ១ នៅជាខាងត្បូង វត្តទាំង ២ នោះ គេទើបនឹងកសាងក្នុងកាលជាខាងក្រោយ មិនមែនកសាងដំណាលគ្នានឹងអង្គរវត្តនោះទេ ———

BIBLIOTHEQUE ROYALE CAMBODGE

ភ្នំបាក់ខែង

ដៃលនឹងទៅពីអង្គរវត្តទៅភ្នំបាក់ខែងនោះ ត្រូវទៅតាមផ្លូវ
ថ្នល់ត្រង់ទៅខាងជើងបំពោះទៅអង្គរធំ ផ្លូវនោះល្អត្រជាក់ស្រួល
ដោយម្លប់ឈើនៅសងខាងផ្លូវ នៅតែ ៤០០ ម៉ែត្រទៀត នឹងដល់
ទៅទ្វារអង្គរធំខាងត្បូង នឹងឃើញភ្នំបាក់ខែងនោះ ស្ថិតនៅជា
ខាងឯលិចផ្លូវ ។

ភ្នំនេះកាលពីដើមឈ្មោះថាឥន្ទ្រទ្វិ គឺភ្នំរបស់ព្រះឥន្ទ្រឬភ្នំ
ជាធំ ដល់មកក្នុងរាជស្តេចឈ្មោះយសោវរ្ម័ន គេបានសាងត្បូ
ប្រាង្គណ៍នឹងប្រាសាទនៅលើភ្នំនោះ ដើម្បីឧទ្ទិសថ្វាយដល់ព្រះ
ឥស្សរ ទើបឲ្យឈ្មោះទីនោះថាយសោធរេស្សរ ។

ដៃលនឹងឡើងទៅលើភ្នំនោះត្រូវទៅដោយផ្លូវ ២ យ៉ាងផ្លូវ ១
ជាផ្លូវចោតពីបាកឡើងទៅណាស់ ផ្លូវនោះកាលពីដើមជាផ្លូវល្អ
មានកាំជណ្តើរសំរាបឡើងទៅស្រួល តែឥឡូវនេះបាក់បែកខូច
អស់ហើយនៅតែជីនឹងឬ ឃើញនៅសល់តែរូបសត្វសីហ ២ នៅ

ត្រង់មាត់ជណ្តើរខាងក្រោម ផ្លូវ ១ ទៀតជាផ្លូវជ្រៀល គេអាចឡើង
ទៅដោយជើងឬបរសេះជិរឡើងទៅក៏បាន ផ្លូវនោះគេធ្វើបត់ប៉ុះ
បត់ឡើង ទើបនឹងធ្វើក្នុងកាលជាខាងក្រោយ ។

កាលបើឡើងតាមផ្លូវចោតដល់ទៅខាងលើកំពូលភ្នំ ត្រូវ
ដើរទៅតាមផ្លូវរៀបឬត្រង់ទៅខាងលិច នឹងឃើញសិវលិង្គគីលិង្គ
ព្រះឥស្សរ ២-៣ នៅតាមផ្លូវនោះ ដើរតរពីនោះទៅនឹងឃើញប្រា-
សាទពីរតូចៗ ធ្វើដោយឬតែឥតមានក្បាច់បម្លាក់អ្វីទេ ដើរបន្តិច
ទៅទៀតនឹងដល់ទៅទីប្រាង្គណ៍ៗ នោះមាន ៥ ប្លាក់ មានជណ្តើរ
ឡើងទៅគ្រប់ប្លាក់ នៅក្បាលជណ្តើរសុទ្ធតែមានរូបសីហ ហើយ
មានប្រាសាទតូចៗជាច្រើននៅគ្រប់ប្លាក់ នៅទីខាងលើប្រាង្គណ៍
មានប្រាសាទ ៥ ប្រាសាទ ១ នៅត្រង់កណ្តាល ប្រាសាទតូចៗ
ឯទៀតនៅគ្រប់ជ្រុងទាំង ៤ ទិស ឯប្រាសាទកណ្តាលនោះគេទើបនឹង
ឃើញក្នុងរវាង ២ ឆ្នាំមុននេះទេ ព្រោះកាលពីដើមប្រាសាទនោះ
មានឬស្រោបជុំវិញ បិទជិតតាំងពីខាងក្រោមរហូតដល់ខាងលើ
ឬដែលស្រោបនោះមានសណ្ឋានជាបល្ល័ង្កព្រះ ហើយមានព្រះ


ពុទ្ធរូបគេធ្វើដំកល់លើប្ដូនោះ តែមិនទាន់ស្រេចទើបនឹងបានត្រឹមព្រះភ្នែន ឯប្ដូដែលស្រោបប្រាសាទ នឹងព្រះពុទ្ធរូបត្រឹមព្រះភ្នែននោះ ប្រហែលជាគេទើបនឹងធ្វើ ក្នុងរវាង ៤-៥ រយឆ្នាំមុននោះទេដឹង តែឥឡូវនេះគេរើយកចេញអស់ហើយ នៅតែប្រាសាទកណ្ដាល ៗ នោះ ក៏បាក់បែកជាច្រើន តែនៅឃើញមានក្បាច់ខាងក្រៅល្អណាស់ដែរ ។

ភ្នំបាក់ខែងនោះ ជាភ្នំគេដើរមើលលេងលើកំពូលសប្បាយណាស់ បើដើរមើលលេងក្នុងវេលាដែលព្រះអាទិត្យ រៀបនឹងអស្ដង្គតនោះរឹងរឹតតែសប្បាយ ព្រោះឥតមានកំដៅព្រះអាទិត្យ កាលបើឈរខាងលើភ្នំហើយ ក្រឡេកមើលទៅជុំវិញ នឹងបានឃើញសព្វគ្រប់ក្បាលមើលណាស់ ទាំងទីអង្គរវត្ត៍មើលទៅឃើញ ព្រោះភ្នំនោះខ្ពស់ជាងដើមឈើទាំងឡាយ ដែលមាននៅក្នុងទីនោះ ។

កាលណារៀបនឹងចុះពីភ្នំបាក់ខែងនោះមកវិញ គួរទៅមើលស្នាមព្រះពុទ្ធបាទ ឬស្នាមព្រះបាទព្រះពុទ្ធ ១ ដែលស្ថិតនៅ

ខាងកើតទីប្រាង្គណ៍ ព្រះបាទនោះគួរឲ្យបង់មើលណាស់ ព្រោះ
គេសាងបង្គងបុះដំរៅបំនួន ៥០ សន្ធឹម៉ែត្រ បណ្តោយបំនួន ២
ម៉ែត្រ ២០ សន្ធឹម៉ែត្រ ហើយមានកុដិប្រកក្បឿងតួប ១ គ្របពីលើ
កុដិនោះ លោកសំយួនទើបនឹងធ្វើ ក្នុងកាលជាខាងក្រោយ
ទេ ។

លុះដល់បុះពីភ្នំនោះមកវិញ ត្រូវទៅតាមផ្លូវដូចបានឥយ
ពីខាងលើហើយ លុះទៅតាមផ្លូវនោះទៅ ក៏ដល់ទៅទ្វារអង្គរធំ
ខាងត្បូង ———



ផែនទីតំបន់ប្រាសាទបាយ័ន តាមបណ្ដោយលោកកូរ

Place centrale d'Angkor Thom (d'après Commaille

អង្គរធំ (នគរធំ)

អង្គរធំបម្រាយពីសៀមរាប ៧៩០០ម៉ែត្រ បម្រាយពីអង្គរវត្ត ១៣០០ម៉ែត្រ អង្គរធំនោះមានស្រះព័ទ្ធជុំវិញ នៅកំផែងនោះមាន ទ្វារ ៥ គឺទ្វារ ២ ខាងកើត ១ ខាងត្បូង ១ ខាងលិច ១ ខាងជើង ឯទ្វារ ២ ខាងកើតនោះ ទ្វារ ១ នៅបំញាក់កណ្តាលត្រង់ពីបាយ័ន ទៅហៅថាទ្វារខ្មោច ទ្វារ ១ ទៀតនៅឆៀងខាងជើង ត្រង់ពីព្រះ លានស្តេចទៅហៅថាទ្វារជ័យ ដែលនឹងទៅតាមទ្វារមួយ ៗនោះ ត្រូវទៅតាមផ្លូវដែលឆ្លងកាត់ស្រះហូលទៅរហូតដល់ទ្វារ ផ្លូវនោះ មានរូបនាគឬនៅជាសងខាង កន្ទុយបែទៅខាងក្នុង ក្បាលចេញ មកខាងក្រៅ រូបនាគម្ខាងមានរូបទេវតាជាប្រើន ដែលប្រដាប់ ដោយមកុដចាប់ទាញរូបនាគ ម្ខាងទៀតមានរូបអសុរជាប្រើន ដែលមានមុខក្រញូវចាប់ទាញ ។

ផ្លូវដែលឆ្លងកាត់ស្រះហូលទៅកាន់ទ្វារទាំងអស់ កាលពី ដើមសុទ្ធតែមានរូបនាគនៅសងខាង ហើយមានទេវតានឹងអសុរ ចាប់ទាញដូចសេចក្តីខាងលើនេះ តែសព្វថ្ងៃនេះបាក់បែកអស់

ហើយ ប៉ុន្តែគេបានរៀបជួសជុលធ្វើផ្លូវដែលទៅតាមទ្វារជ័យឲ្យ
មានរបៀបជួបពីដើមទ្បើងវិញ ឯទ្វារទាំង ៥ នោះមានទំហំធំដូច
សណ្ឋានជួបគ្នា មានកំពស់ជាង ៣ ម៉ែត្រ ទ្វារនោះឯងសុទ្ធតែ
មានក្បាច់បម្លាក់ទាំងខាងក្នុងខាងក្រៅ ហើយមានរូបក្បាលជំរី
នៅសងខាងត្រង់ផ្ទៃងទ្វារ ឯខាងលើទ្វារនោះប្រដាប់ដោយមុខ ៤
បែទៅគ្រប់ទិសទាំង ៤ ។

ឯមុខទាំង ៤ ដែលនៅលើទ្វារនោះគេតែងបួលបិត្តផ្សេង ៗ
គ្នា ខ្លះបួលបិត្តជាមុខព្រហ្ម ខ្លះជាមុខព្រះឥសូរ ធំឯរកឲ្យប្រាកដ
មិនឃើញ តែឥឡូវនេះមានអ្នកប្រាជ្ញបារាំង ១ ជាក់ - ឈ្មោះ
ល្វី-ហ្វីណូត លោកបានទៅសង្កេតមើលសព្វកន្លែងនៅទីអង្គរ
ក៏បានឃើញរូបព្រះពោធិសត្វឈ្មោះ អវលោកិតេស្វរ ជាប្រើន
នៅតំឯប្រាសាទទាំង ៤ ដែលមាននៅត្រង់ផ្ទៃងកំផែងខាងក្រៅ
ទាំង ៤ តំឯហោជាងប្រាសាទក្លាងទ្វារអង្គរធំ តែហោជាងនៅ
គ្រប់ទ្វារទាំងអស់ផ្ទៃសបាក់អស់ហើយ ឃើញសល់នៅតែហោ-
ជាងខាងក្នុងទ្វារជ័យ ១ ហោជាងនោះក៏របេះបង្កាក់ខ្លះ ប៉ុន្តែនៅ
មានរូបបម្លាក់អាចឲ្យសង្កេតទៅយល់ប្បាស់ប្រាកដបាន ថាជា

រូបអរិលោកិតេស្វរ ទាំងហោជាងប្រាសាទបាយ័ន ក៍លោក ហ្វីណូត៍ បានសង្កេតទៅឃើញមានរូបអរិលោកិតេស្វរ ដែលជា អ្នកគ្រប់គ្រងរក្សាអស់ទាំងអ្នកកាន់ព្រះពុទ្ធសាសនា (តាមលទ្ធិ ពុទ្ធសាសនាខាងមហាយាន) លោកហ្វីណូត៍បានសង្កេតទៅ ឃើញដូចនេះ ក៍ប្លែបិត្តជាអង្គរធំនេះជាទី គឺអ្នកកាន់ព្រះពុទ្ធ សាសនាខាងមហាយាន បានការសាងឡើងជាមុន ។

ហេតុដូចនេះគួរតែប្លែបិត្តជា មុខដែលនៅលើទ្វារទាំង អស់ ប្រហែលជាមុខអរិលោកិតេស្វរ ព្រោះគេធ្វើឲ្យបែរទៅគ្រប់ ទិសទាំង៤ដូចនេះដោយសំដែងឲ្យឃើញជាព្រះអរិលោកិតេស្វរ ឯកមើលទៅក្នុងទិសទាំង ៤ ដើម្បីនឹងជួយអភិបាលរក្សាអស់ ទាំងអ្នកកាន់ព្រះពុទ្ធសាសនា ដែលនៅក្នុងទិសទាំង ៤ ។

គ្រប់ទ្វារទាំងអស់ ត្រង់កន្លែងរង្វង់ទ្វារទាំងសងខាង មាន ជណ្តើរ ៣-៤កាំ សំរាបឡើងទៅកាន់បន្ទប់ទាំងសងខាង ។

កាលណាបើគេប្លែបតាមទ្វារទាំងនោះទៅ ក៍ដល់ទៅខាង ក្នុងទីក្រុងអង្គរធំៗនេះ ជាទីក្រុងចាស់ឈ្មោះហ៊ា យសោធរបុរ ដែលស្តេចឈ្មោះហ៊ា យសោវរ៉ាមន ទ្រង់សោយរាជ ទីក្រុងនោះ

មិនបានស្ថិតនៅមាំមួនជានិច្ចទេ ដូនកាលគេលះបង់ចោលទី
នោះ ហើយទៅតាក់តែងកន្លែងដទៃជាទីក្រុង ដូនកាលត្រឡប់
មកយកទីអង្គរធំនេះជាទីក្រុងវិញ លុះយូរៗមកដល់មកស្ដេច
ជាន់ក្រោយ ក៏ចោះបង់ចោលទីក្រុងអង្គរធំនេះមែនទែន ដោយ
ហេតុពីតសិកសង្គ្រាមមានសត្រូវលុកលុយចូលមក ។

តាមសៀវភៅរបស់បិណាឈ្មោះ ចាវតាកួន គេនិយាយថា
អង្គរធំជាទីក្រុងធំណាស់ បរិបូណ៌ដោយទ្រព្យសម្បត្តិនឹងកុសល
ដោយច្រើនសន្ធឹកជាច្រើន ។

កាលបើចូលទៅតាមទ្វារខាងត្បូងហើយទៅតាមផ្លូវថ្នល់ត្រង់
ទៅចំនួន ១៤០០ ម៉ែត្រក៏ដល់ទៅទីវិហារស្ថានបាយ័ន ⁂—

ក្បាច់ចម្លាក់ថ្ម ពេទ្យជុំឈ្នះនាគ ប្រាសាទបាយ័ន

បាយ័ន

ទីបាយ័ននេះស្ថិតនៅបំពាក់កណ្តាលក្រុង បាយ័ននេះប្រហែលជាទីចាស់ជាងប្រាសាទដទៃៗក្នុងអង្គរធំ កាលបើក្រឡេកមើលទ្រង់ទ្រាយ តាំងពីខាងក្រោមជារាបជាល់ទៅកំពូល ឃើញមានទ្រង់មានសណ្ឋានដូចជាភ្នំ ព្រោះហេតុនេះបានជាពីដើមគេឲ្យឈ្មោះបាយ័ននោះហ៎ា យសោធរគិរិ គឺភ្នំទ្រទ្រង់នូវយស ។

ទីបាយ័ននេះ អស់ពួកមេការបាំងនឹងពួកអ្នកប្រាជ្ញបាំងបានមកពិនិត្យសង្កេតមើល បែបផែននឹងទំនងការការសាងឃើញថាបាយ័ននេះ មិនមែនគេសាងតែម្តងទេ គឺធ្វើប្រើនលើកប្រើនដង បានជាឃើញមានឬស្ថិតនៅជាសង្កាត់ៗ ជាជាន់ៗ រងឹបរដុបប្រើន ត្រង់ជាន់ទី ៣ លុះជាល់គេរើអស់ទាំងឬ ដែលជំរួតលើគ្នានោះបេញ្ចេះទៅ ក៏ឃើញរូបបម្លាក់ អរិលោកិតេស្សរនៅទីខាងក្នុងនោះ កាលបើឃើញដូចនេះហើយក៏គេនឹកស្មានថាទីបាយ័ននេះ កាលពីដើមប្រហែលជាពួកអ្នកកាន់ព្រះពុទ្ធសាសនាខាងមហាយាន គេបានការសាងលុះជាល់មកជាន់ក្រោយទំនង

ជាពួកអ្នកកាន់សាសនាព្រាហ្មណ៍ មកនៅបែរក្បាទីបាយ័នឆេះ
ក៏យកដុំថ្មទៅជាក់ខ្ទប់បិទរូបអរិណោកតេស្សរនោះ មិនឲ្យគេមើល
ទៅឃើញ មិនតែប៉ុណ្ណោះទេ្បយគេបានសង្កេតមើលនៅសសរ
ឃើញរូបបម្លាក់ បំណែកខាងព្រះពុទ្ធសាសនា តែមិនច្បាស់
ដោយមានស្មៅគោសលុបរូបនោះចេញ ហើយធ្លាក់រូបបំណែក
ខាងសាសនាព្រាហ្មណ៍ទ្បើងវិញត្រង់កន្លែងនោះ ។

បាយ័នឆេះប្រកបដោយជាន់ ៣ មានទ្វារសំរាបចូលទៅ
បានគ្រប់ទិសទាំង ៤ តែទ្វារធំនៅជាខាងកើត ហេតុនោះគួរតែ
នឹងចូលទៅតាមទ្វារខាងកើត បើចូលទៅតាមទ្វារខាងកើត មុន
ដែលនឹងចូលទៅនឹងឃើញទីធ្លៀប្ដ ១ ខ្ពស់ពីផែនដី ស្មើគ្នានឹងធ្លៀ
ជាន់ទី ១ ក្នុងបាយ័ន ទីធ្លៀប្ដនោះវែងត្រង់មកខាងកើត មាន
ជណ្ដើរបំនួន ៧-៨ កាំ សំរាបឡើងពីខាងកើត កាលបើទ្បើង
តាមជណ្ដើរនោះដល់ទៅខាងលើទីធ្លៀប្ដ នឹងឃើញរូបសត្វសីហ
ត្រង់ក្បាលជណ្ដើរខ្លះនឹងរូបនាគជាប្រកាន់ដៃនៅត្រង់ក្បាលនាគ
នោះឃើញមានរូបគ្រុឌជិះលើក្បាលនាគ រូបសត្វដែលជាគ្រឿង
ប្រដាប់នៅទីនោះឃើញមានភាពទំនងជារបស់ខ្មែរហើយឃើញ

មានកន្លែងស្រះ ២ នៅជាសងខាងទីផ្ទៃនោះ លុះដើរតាមទីផ្ទៃឬ
នោះទៅ ក៏ដល់ទៅជាន់ទី ១ ។

ជាន់ទី ១ – ជាន់ទី ១ នេះ គ្រង់កន្លែងដែលឫលទៅ ឃើញមាន
កន្លែងទ្វារ ២-៣ សង្កាត់ នៅទ្វារនោះកាលពីដើមប្រហែលជាគេ
ធ្វើមានដំបូលជាយ៉ាងម៉ាប់គ្នាពីពាងថែរជាន់ទី ១ មក តែឥឡូវនេះ
បាក់បែកខ្ទេចអស់ហើយ ឃើញនៅតែសសរ ។ ទាំងនោះ មាន
ក្បាច់បម្លាក់ជារូបល្មោនល្អណាស់ ទៅពីកន្លែងទ្វារបន្តិចទៅ ក៏
ដល់ទៅកន្លែងពាងថែរ ។ នោះ កាលពីដើមមានដំបូលជុំវិញ តែ
ឥឡូវនេះបាក់បែកអស់ហើយ ឃើញនៅតែសសរតឹងជញ្ជាំង ឯ
សសរពាងថែរជុំវិញនោះ ឃើញមានក្បាច់បម្លាក់ជារូបល្មោនដូច
សសរទ្វារខាងក្រៅ ឯជញ្ជាំងជុំវិញនោះឃើញមានក្បាច់បម្លាក់
រម្លេប និយាយពីរឿងរ៉ាវផ្សេង ។ ហើយតឹងរឿងពង្សាវតារ ជា
ក្បាច់រម្លេបល្អណាស់ ក្នុងរឿងទាំងអស់នោះ សង្កេតមើលទៅ
ឃើញគ្រឿងប្រដាប់ធ្វើការ គ្រឿងភ្លេងតឹងគ្រឿងប្រដាប់អ្នកនេ-
សាទ ក៏ឃើញដូចគ្នាតឹងគ្រឿងប្រដាប់ដែលគេប្រើប្រាសសព្វថ្ងៃ
នេះដែរ ហើយឃើញអស់ទាំងមនុស្សជាតិផ្សេង ។ មានសម្លៀក
បំពាក់តាមទម្លាប់របស់ជាតិនោះ ។ ជង ។ ល ។ ល ។

កាលបើមើលក្បាច់រម្លេបនៅជញ្ជាំងថែរជាន់ទី ១ រួចហើយ ត្រូវឡើងទៅកាន់ជាន់ទី ២ នៅត្រង់ទីផ្ទៃឬជាបន្លោះជាន់ទី ១ និង ទី ២ មានបណ្ណាល័យ ២ មួយនៅត្រង់ជ្រុងទិសឦសាន មួយ ទៀតនៅត្រង់ជ្រុងទិសអគ្នេ ។

ជាន់ទី ២ – ជាន់ទី ២ នេះមានរោងថែរព័ទ្ធជុំវិញ នៅរោង ថែរនោះ គេធ្វើជាប្រាសាទមានកំពូលខ្ពស់ឡើងចំនួន ១៦ ប្រាសាទ នៅត្រង់ជ្រុងទាំង ៤ នៃរោងថែរខាងក្នុងមានរោងថែរជា រំពត់ព្រោបតាមជ្រុង នៅរោងថែរជ្រុងមួយ ។ មានប្រាសាទ ខ្ពស់ឡើងបី ។ កំពូលប្រាសាទទាំងអស់នោះ សុទ្ធតែប្រដាប់ ដោយមុខ ៤ ។ នៅជញ្ជាំងរោងថែរជុំវិញមានក្បាច់រម្លេបនិយាយ ពីរឿងអស្ចារ្យខាងបំណែកសាសនាព្រាហ្មណ៍ ។

ជាន់ទី ៣ – ជាន់ទី ៣ នេះមានទីផ្ទៃឬខ្ពស់ឡើងជាងជាន់ទី ២ ត្រង់កណ្តាលទីផ្ទៃនោះមានប្រាសាទ ១ ខ្ពស់ធំជាង ប្រាសាទទាំង ២០ ជុំលមានទៅជោយជុំវិញ ឯកំពូលប្រាសាទ កណ្តាល ព្រមទាំងប្រាសាទទាំង ២០ នោះ សុទ្ធតែប្រដាប់ ដោយមុខ ៤ ទាំងអស់ ខាងក្នុងប្រាសាទកណ្តាល កាលពីដើម

មានទីកន្លែងសំរាប់ជំរកលំនៅព្រះឥសូរ នៅក្នុងបន្ទប់ខ្លះដែលមាននៅនឹងប្រាសាទកណ្តាលនោះ ឃើញមានព្រះពុទ្ធរូបខាងលទ្ធិហីនយាន តែព្រះពុទ្ធរូបទាំងនោះ គេទើបនឹងយកទៅដាក់ក្នុងកាលជាខាងក្រោយទេ ។

បណ្តាក្បាច់បម្លាក់ ដែលមាននៅទីអង្គរធំ ឃើញមានក្បាច់បម្លាក់នៅប្រាសាទនោះត្រង់ទីអមសងខាងទ្វារ បង្ហួច គឺងខាងលើខាងក្រោមទ្វារ បង្ហួច ជាក្បាច់បម្លាក់ល្អសំខាន់ ដោយបែប ១ យ៉ាងដែរ ។

ទីបាយ័ននោះបើទ្បើងទៅដល់ជាន់ទី ៣ ក្នុងវេលាដែលព្រះអាទិត្យ ហៀបនឹងអស្តង្គតនោះល្អមើលណាស់ ព្រោះប្រាសាទទាំងអស់ឃើញហាក់ដូចជាផុសលេចចេញពីក្នុងព្រៃ កាលណារស្មីព្រះអាទិត្យចាំងមក ក៏ឃើញអស់ទាំងមុខ ៤ ដែលនៅនឹងកំពូលប្រាសាទទាំងអស់ ដូចជាញញឹមគ្រប់មុខទាំងអស់ ។


កាលបើបុះពីបាយ័នមក ត្រូវដើរទៅតាមផ្លូវប្តូលខាងត្បូងវង់ទីបាយ័ននោះ នឹងឃើញបេតិយ មានសណ្ឋានជាប្រាសាទតូច ១ នៅប្រចាំផ្លូវដែលគេទើបនឹងធ្វើ ដើម្បីទុកជាគ្រឿងរឭក

ដល់លោក កុម្ម៉ែ ដែលជាអ្នកគ្រប់គ្រងបែរក្បាទីអង្គុរនោះមុនគេ លុះដល់មកខាងទិសពាយព្យ នឹងឃើញវិហារប្ញ ១ គេទើបនឹងសាងនៅជិតផ្លូវប្ញល់ ក្នុងវិហារនោះ មានព្រះពុទ្ធរូបបួលនិព្វាន ១ ព្រះអង្គុល្លណាស់ ជាព្រះពុទ្ធរូបខាងលទ្ធិហីនយាន គេសាងប្រហែលជាក្នុងរវាង ៤-៥ រយឆ្នាំមុននេះ តែព្រះពុទ្ធរូបនោះសព្វថ្ងៃនេះគេលើកដាក់ជំកល់លើបល្ល័ង្កជាមួយគ្នា នឹងព្រះពុទ្ធរូបប្ញីដែលគេទើបនឹងសាង ។

នៅខាងទិសពាយព្យនៃបាយ័ន មានប្រាសាទជាច្រើន មានប្រាសាទបាពួនជាដើម ទីត្រង់នោះហើយដែលជាទីបរមរាជវាំងពីដើម ។

ប្រាសាទបាពួន

ដែលនឹងទៅកាន់ប្រាសាទបាពួននោះ បើទៅតាមផ្លូវប្ញល់ត្រង់ទៅខាងជើង ដល់ទៅទីខាងមុខបាពួនត្រូវឡើងតាមជណ្តើរ ហើយដើរត្រង់ទៅខាងលិចទៅក៏បាន ឬទៅកាត់ព្រៃចូលទៅតាមផ្លូវជើងប្រៃបរិហារប្ញី ដែលនៅខាងទិសពាយព្យនៃបាយ័នក៏បាន បើទៅតាមផ្លូវកាត់ព្រៃចូលទៅបំនួន ៣០០ ម៉ែត្រក៏ដល់ទៅប្រាសាទបាពួន ។



ក្បាងទ្វារគេទទួលស្រីលស៊ាសនាព្រាហ្មណ៍

ប្រៀបធៀបនឹងរូបភាពលំដាប់ទាប និងព្រះនន្ទិហ្គ្រអង្គុយលើផ្កាឈូក

ប្រាសាទបាពួននេះគឺស្តេចឈ្មោះជ័យវរ៉ាមន៍ទី ៥ បានសង់
នៅលើទីខ្ពស់តួប ១ ដើម្បីឧទ្ទិសថ្វាយដល់ទេវតាខាងសាសនា
ព្រាហ្មណ៍ឈ្មោះហេមស្រិង្គេស (ទេវតាជាធំប្រកបដោយស្នែង
មាស) ប្រាសាទនោះកាលពីដើមឈ្មោះថាហិមាទ្រិ (ភ្នំមាស)
នៅខាងលិចជិតជើងប្រាសាទនោះ កាលពីដើមឃើញមានប្តីគេ
រៀបខ្ពស់ឡើងមានសណ្ឋាន ជាព្រះពុទ្ធរូបបួលនិញាន ចាំងទី
ប្រាសាទខាងលិច ឬដែលរៀបដូចនេះប្រហែលជាពួកអ្នកកាន់
ព្រះពុទ្ធសាសនាខាងហីនយាន បានរៀបធ្វើឡើងក្នុងកាលជា
ខាងក្រោយ តែឥឡូវនេះគេកំពុងតែរើឬនោះចេញ ។

ប្រាសាទនោះមានជាន់ ៣ ធំឯប្រកបដោយរោងថែវ មាន
ជណ្តើរសំរាប់ឡើងទៅគ្រប់ទិសទាំង ៤ តែសព្វថ្ងៃនេះឡើងបាន
ទៅស្រួលតែតាមជណ្តើរខាងត្បូង ។

សៀវភៅបិណឈ្មោះចារិតកួនន័យយថា ប្រាសាទនោះ
ជាប្រាសាទធំខ្ពស់ល្អសំខាន់ ១ ក្នុងពួកប្រាសាទដែលមាននៅទី
អង្គរធំ ហើយថាត្រង់កណ្តាលជាន់ទី ៣ មានប្រាសាទ ១ តែ
សព្វថ្ងៃនេះ ត្រឡប់ទៅជាបាក់បែកច្រើនជាងប្រាសាទឯទៀត ។

នៅទីជញ្ជាំងសងខាងទ្វារទាំងអស់ក្នុងជាន់ទី ២ ឃើញមានក្បាច់រម្លេចជាសង្កាត់ៗ ល្អណាស់ សុទ្ធតែនិយាយពីរឿងអស្ចារ្យ ខាងបំណែកសាសនាព្រាហ្មណ៍ ទំងរឿងរាមាយណ។

កាលបើបេញមកវិញ ត្រូវដើរមកតាមផ្លូវឬត្រង់មកខាងកើត ឯផ្លូវនោះកាលពីដើមជាប្ញស្ន មានសណ្ឋានដូចជាស្ពានព្រោះមានសសរឬទល់ទ្រពីក្រោម តែឥឡូវនេះបាក់បែកអស់ហើយ សល់នៅតែសសរ ប៉ុន្តែគេបានរៀបបំលើកដុំថ្មជាក់លើក្បាលសសរតរៗគ្នាល្អមដើរបាន លុះដើរតាមផ្លូវនោះមកជិតបានជិតមកមាត់ជណ្តើរ ក៏ចុះដើរទៅខាងជើង ទំងឃើញទីព្រះលានស្តេច។

ទីព្រះលានស្តេច

ទីព្រះលាននេះស្ថិតនៅខាងជើងត្រង់ពីបាយ័នមក មានផ្ទៃខ្ពស់ឡើងពីផែនដី ទទឹងបំនួន ១៤ ម៉ែត្រ បណ្តោយបំនួន ៣០០ ម៉ែត្រ រៀបត្រង់ដូចជាកំផែងពីខាងត្បូង ទៅខាងជើង មានរូបនាគជាប្រាកន់ដៃទាំងសងខាង ទីព្រះលាននោះប្រហែលជាទីសំរាប់ស្តេចយាងបេញមកក្រសាល ដើម្បីទំងទតអស់ទាំងមនុស្សដែលដើរតាមផ្លូវ។

ទីព្រះលានឆេះមានទីយ៉ាលយចេញមកខាងកើត ៥ កន្លែង គឺទីយ៉ា ៣ នៅត្រង់កណ្តាល ទីយ៉ាពីរទៀត នៅទីបំផុតទាំងសងខាង នៅត្រង់កើយ ទីយ៉ាបំផុតទាំងសងខាង មានបម្លាក់រម្លេចជារូបជំរី ត្រង់កើយទីយ៉ាកណ្តាល មានបម្លាក់រម្លេចជារូបគ្រុឌដួចជាទ្រទីនោះ ត្រង់កើយទីយ៉ាតូចៗទាំងសងខាងមានបម្លាក់រម្លេចជារូបជំរី ត្រង់កើយទីព្រះលានបែកខាងត្បូងមានបម្លាក់រម្លេចជារូបជំរីដែរ បែកខាងជើងមានបម្លាក់រម្លេចជារូបគ្រុឌ ។

កាលបើត្រូវការនឹងទៅមើលប្រាសាទវិមានអាកាស ត្រូវឡើងតាមជណ្តើរត្រង់ទីយ៉ាកណ្តាល ឡើងដល់ទៅខាងលើទីព្រះលាននឹងឃើញរូបសត្វសីហនៅជាសងខាង ហើយឃើញមានរូបនាគជាប្រាកន់ដៃជិង លុះដើរត្រង់ទៅខាងលិចនឹងដល់ទៅទ្វារកំផែង តរពីទ្វារកំផែងនោះទៅ ប្រហែលជា ១៥០ ម៉ែត្រក៏ដល់ទៅវិមានអាកាស ~—

វិមានអាកាស

វិមាននេះស្ថិតនៅត្រង់កណ្តាលព្រះបរមរាជវាំង គេបាប់ធ្វើឡើង ក្នុងរាជស្តេចទ្រង់ព្រះនាម យសោវរ៉ាមន ដល់មកក្នុងរាជ

ស្តេចទ្រង់ព្រះនាមហសិរិរម័ននេះបហើយស្រេច វិមាននោះមាន
សណ្ឋានជាតួប្រាង្គណ៍ប្រែកបដោយជាន់ ៣ ត្រង់ជាន់ខាងលើ
មានរោងបៃរិតួបព័ទ្ធជុំវិញ មានជណ្តើរ ៤ សំរាប់ឡើងទៅលើទី
ប្រាង្គណ៍នោះគ្រប់ទិសទាំង ៤ តែឯជណ្តើរដែលឡើងទៅស្រុល
នោះ គឺជណ្តើរទិសខាងលិច ត្រង់ផ្លែកណ្តាលជាន់ទី ៣ មាន
ប្រាសាទ ១ តែឥឡូវនេះបាក់បែកជាច្រើនណាស់ហើយ វិមាន
នេះគេសាងដើម្បីបូជយដល់ទេវតា ដែលជាអ្នករក្សាទីបរមរាជវាំង
ព្រមទាំងព្រះញាតិវង្សានុវង្ស ។

តាមសៀវភៅបិណាឈ្មោះ ចាវតាកួន គេនិយាយថា មាន
រឿងព្រេងថា ស្តេចតែងយាងមកជួបក្រសាលសប្បាយ ដោយ
នាងនាគីនៅប្រាសាទនោះរាល់ល្ងាច ។

វិមាននេះល្អមើលណាស់ ព្រោះគេធ្វើដោយប្លែបាយក្រៀម
លាយដោយប្លែពណ៌ប្រផេះខ្លះ ។

កាលចេញពីវិមានអាកាស គួរទៅមើលកន្លែងស្រះចាស់
ពីបួរណា ១ ស្រះនោះស្ថិតនៅត្រង់ពីខាងជើងវិមានអាកាស
ដែលនឹងទៅមើលស្រះនោះ ត្រូវដើរតាមផ្លូវជើង កាត់ព្រៃទៅ

ខាងជើងចំនួន ១០០ ម៉ែត្រ ក៍ដល់ទៅកន្លែងស្រះ នៅមាត់ស្រះ នោះមានឬជាប្អាក់ៗបីប្អាក់សំរាបបុះទៅក្នុងស្រះនៅប្អាក់ឯមួយៗ សុទ្ធតែមានក្បាច់រម្លេចជារូបផ្សេងៗ ប្អាក់ខាងក្រោមឃើញមានរូបសត្វទឹកមានត្រីនឹងមករជាដើម ប្អាក់កណ្តាលឃើញមានរូបនាគានឹងនាគីនឹងរូបមនុស្សខ្លះ ប្អាក់ខាងលើឃើញមានរូបទេវតាយក្ស នឹងគ្រុឌ ប្អាក់ទាំង ៣ នេះប្រហែលជាគេធ្វើដោយទុកជាប្រស្នា ប្អាក់ក្រោមទុកជាទឹក ប្អាក់កណ្តាលទុកជាផែនដី ប្អាក់លើទុកជាអាកាស ។

កាលបើមើលទីស្រះនោះរួចហើយ ត្រូវដើរត្រឡប់មកកាន់ផ្លូវខាងមុខវិមានអាកាសវិញ ហើយដើរមកខាងកើត តាមផ្លូវដ៏ដៃល ដរាបមកដល់ទីព្រះលានស្ពេប លុះបុះពីទីព្រះលាននោះមក ដាកដើរទៅខាងជើងបន្តិច ក៍នឹងឃើញទីលាន ១ ឈ្មោះថា ទីលានស្ពេបគម្ពង់ ~—

ទីលានស្ពេបគម្ពង់

ទីលាននេះស្ថិតនៅជាខាងជើងទីព្រះលានស្ពេប បម្ងាយប្រហែល ២-៣ ម៉ែត្រពីគ្នា មានកំពស់ជាង ៦ ម៉ែត្រ ដៃលនឹង

ទ្បើងទៅលើទីលាននោះ ត្រូវបួលទៅតាមផ្លូវត្បូប ១ បត់បុះទ្បើង ក្នុងទីលាននោះ លុះដល់ទៅខាងលើ ក៏នឹងបាន‌ឃើញរូប ១ ដែលគេហៅថា រូបស្តេចគម្លង់[1] នៅជញ្ជាំងខាងក្រៅនឹងខាង ក្នុងទីលាននោះ ឃើញមានរូបបម្លាក់រម្លេចជារូបនាគ នឹងរូប ទេវតាជាច្រើន ។ ល ។

កាលបើបុះពីទីលាន‌ស្តេចគម្លង់មក ត្រូវទៅតាមផ្លូវជើង កាត់ព្រៃត្រង់ទៅទិសឦសាន‌ប្រមាណជាង ១០០ ម៉ែត្រ ក៏ដល់ទៅទី ១ ហៅថាទេពប្រណម្យ ឬនឹងទៅតាមផ្លូវឆ្ពោះខាង មុខក៏បាន ទៅពីទីលាននោះទៅចំនួន ១០០ ម៉ែត្រមានផ្លូវជើង ១ បែកទៅខាងលិច ដើរតាមផ្លូវនោះទៅ ក៏ដល់ទៅទីទេព-ប្រណម្យដូចគ្នា ។

ទេពប្រណម្យ

ទេពប្រណម្យនេះ ជាទីលានដីដែលគេរៀបចំបំរុងនឹងធ្វើ វិហារខាងព្រះពុទ្ធសាសនា នៅលើទីលានចំផុតខាងលិច ឃើញ មានព្រះពុទ្ធរូបបដិ ១ ព្រះអង្គ ពែនលើបល្ល័ង្កបែព្រះភក្ត្រទៅខាង

---

(១) រូបនេះអ្នកខ្លះគេយល់ថាជារូបព្រះឥសូរ ។

កើត មានកំពស់ ៤ ម៉ែត្រ ឯព្រះពុទ្ធរូបនោះមើលទៅឃើញសំ-
បើមល្អណាស់ ព្រោះនៅក្នុងព្រៃស្ងាត់តែ ១ ព្រះអង្គ ហើយសក្តិ
សមល្អ តាំងពីព្រះភក្ត្រដរាបដល់ព្រះភ្នែន នៅលើទីលានខាង
មុខព្រះពុទ្ធរូបនោះ ធ្វើឯងខាងឆ្វេងបន្តិចមានសសរឬ ៤ ជ្រុង ១
ប្រកបដោយសិលាចារឹក និយាយសរសើរពីបុណ្យស្តេចទ្រង់ព្រះ
នាមយសោវរ្ម័ន តឹងនិយាយពីការការសាងទឹកន្លែង ខាងព្រះ
ពុទ្ធសាសនា សសរឬព្រមទាំងសិលាចារឹកនោះ សព្វថ្ងៃនេះនៅ
ល្អទាំងអស់ នៅខាងក្រោយព្រះពុទ្ធរូបនោះ ផុតពីទីលាននោះ
ទៅ ឃើញមានព្រះពុទ្ធរូបទ្រង់ឈរ ១ ព្រះអង្គ សំដៅឯងអាការ
ព្រះហស្តជាអភយមុទ្រ គឺវាព្រះហស្ត តែព្រះពុទ្ធរូបនោះសព្វថ្ងៃ
នេះរបេះរបកត្រង់ព្រះភក្ត្រអស់ នៅសល់តែខាងព្រះសរ ល—

ព្រះបាលិខ្មៅ[1]

ប្រាសាទបាលិខ្មៅនេះស្ថិតនៅជាខាងលិច ធ្វើឯងខាងជើង
ទេពប្រណាម្យ មានមុខបែរទៅខាងកើត នៅទីប្រាសាទនោះមាន

---

(១) ពាក្យថាបាលិខ្មៅនេះ ជាពាក្យច្វាយមកពីភាសាថៃថា បាលីសេយ្យក ជាឈ្មោះព្រៃ
១ ដែលព្រះសាក្យមុនីទ្រង់យាងចេញតែ ១ ព្រះអង្គឯក្រៅពីសម្តី ហើយទៅគង់នៅក្នុងព្រៃនោះ។

ក្បាច់បម្លាក់ល្អណាស់ឃើញមានរូបបម្លាក់ខាងព្រះពុទ្ធសាសនា
មហាយានដោយប្រើនហើយឃើញមានរូបបម្លាក់ខាងសាសនា
ព្រាហ្មណ៍ខ្លះដែរ ដូចជានៅប្រាសាទកណ្តាល ត្រង់មេទ្វារខាង
លើទិសខាងកើត ឃើញរូបព្រះឥន្ទ្រជិះលើដំរីឈ្មោះវិណា មាន
ក្បាល ៣ ត្រង់មេទ្វារខាងលើទិសខាងលិច ឃើញមានរូបព្រះ
ព្រហ្មជិះលើហង្ស នៅសុំទ្វារប្រាសាទខាងកើត ឃើញមានព្រះ
ពុទ្ធរូប គឺងប្ដូដៃលបាក់ធ្លាក់ចុះមកខាងក្រោម ក៏ឃើញមានព្រះ
ពុទ្ធរូបជាប្រើន នៅខាងមុខប្រាសាទនោះ មានទីលានឬ ១ មាន
ជណ្ដើរសំរាប់ចុះទៅឯគ្រប់ទិសទាំង ៤ នៅសងខាងទីលាននោះ
មានរូបនាគជាប្រកាន់ដៃ ——

ព្រះពិធ្លរ

នៅខាងកើតទេពប្រណាម្យ មានពួកប្រាសាទជាប្រើន
ហៅថាព្រះពិធ្លរ ក្នុងពួកប្រាសាទទាំងនោះ ប្រាសាទខ្លះគេធ្វើ
ដើម្បីទុទ្ទិស្សដល់ព្រះពុទ្ធសាសនា ខ្លះដើម្បីទុទ្ទិស្សដល់សាសនា
ព្រាហ្មណ៍ ក្នុងព្រះពិធ្លរនោះ មិនមានតែប្រាសាទនោះៗទេ ឃើញ
មានទាំងទីលានគងស្រះផង រួមទីនោះទាំងអស់ហៅថាព្រះពិធ្លរ

ឯក្បាច់បម្លាក់ដែលមានក្នុងប្រាសាទទាំងនោះ ជាក្បាច់ល្អគ្រាន់បើដែរ ។

កាលបើដើរត្រង់ទៅខាងកើតជាល់ទៅមាត់ស្រះធំឯងឃើញរូបជំរឹប្ដីគួរល្អណាស់មានទ្រង់ហាក់ដូចជាជំរឹរស់មែនទែន ——

ឃ្លាំង

កាលបើដើរចេញពីព្រះពិឆ្ងរ ទៅតាមផ្លូវខាងត្បូង ឆ្ងាយបាន ឃើញប្រាសាទ ២ ដែលគេហៅថាឃ្លាំង នៅអមសងខាងផ្លូវ ដែលជាផ្លូវត្រង់ទៅលើទ្វារជ័យ ឯឃ្លាំងទាំង ២ នោះ ឃ្លាំងមួយៗ មានប្រាសាទតូចៗ-ប្រាំៗ ស្ថិតនៅពីខាងលិចជាជួរ ពីខាងជើងទៅខាងត្បូង ឯប្រាសាទតូចៗនោះ បើតាមរឿងព្រេងនិយាយថា ប្រាសាទទាំងនោះជាទីសំរាប់បងព្រាត់ ហើយដើរស្ងរលើព្រាត់នោះ ។ សព្វថ្ងៃនេះគេកំពុងតែរៀបចំឃ្លាំងនោះធ្វើឲ្យស្អាតល្អឡើងវិញ ។

កាលបើមើលប្រាសាទក្នុងទីអង្គរធំរួចហើយ ត្រូវទៅតាមផ្លូវជាបន្លោះឃ្លាំងទាំង ២ នោះ ត្រង់ទៅខាងកើតទៅតាមផ្លូវនោះទៅមិនឆ្ងាយប៉ុន្មានក៏ឆ្ងាយដល់ទៅទ្វារជ័យ លុះចេញពីទ្វារជ័យ

នោះទៅ ត្រូវទៅតាមផ្លូវដូចបានន័យយ ពីខាងជើមរូបហើយ ទៅតរពីផ្លូវនោះត្រង់ទៅខាងកើតបន្តិចទៅ ក៏នឹងឃើញប្រាសាទ ២ ប្រាសាទ ១ នៅខាងជើងផ្លូវ ឈ្មោះថាប៉ុម្មាណុន[1] ប្រាសាទ ១ ទៀតនៅខាងត្បូងផ្លូវ ឈ្មោះថាបៅសាយ ប្រាសាទទាំង ២ នោះ គេធ្វើជើម្បីទុទ្ទិស្សដល់សាសនាព្រាហ្មណ៍ ទៅតរពីនោះ បន្តិចទៅទៀតនឹងដល់ទៅស្ទឹងសៀមរាបហើយនឹងឃើញកន្លែងស្ពានឬចាស់បាក់បែកពីបួរណា ១ នៅប្រៃបស្ពានឈើ ដែលគេទើបនឹងធ្វើថ្មី ទៅតរពីស្ទឹងនោះបន្តិចទៅ ហើយបែទៅខាងត្បូងតាមផ្លូវប្លង់ នឹងឃើញប្រាសាទ ១ ឈ្មោះថា ប្រាសាទតាកែវ ដូចមាន—

ប្រាសាទតាកែវ

ប្រាសាទតាកែវនេះជាប្រាសាទល្អ ១ ក្នុងទីអង្គរ គេសាងក្នុងរវាងពុទ្ធសករាជ ជាង ១៥០០ ជើម្បីទុទ្ទិស្សឲ្យដល់សាសនាព្រាហ្មណ៍ ។

---

(១) ឈ្មោះនេះប្រហែលជាក្យពីពាក្យថា ធម្មនន្ទទេនឹង ។

ដែលនឹងចូលទៅកាន់ប្រាសាទនោះ ត្រូវទៅតាមផ្លូវខាងកើត ទីទ្រប្រាសាទនោះមាន ៣ ជាន់ នៅជាន់ទី ២ មានរោងបែរព័ទ្ធជុំវិញ ហើយមានបណ្ណាល័យ ២ នៅសងខាងទ្វារខាងកើត ជាន់ទី ៣ មានសណ្ឋានជាតួប្រាង្គណ៍ ៣ ជ្រុក នៅលើប្រាង្គណ៍នោះ មានប្រាសាទ ៥ ប្រាសាទកណ្តាលធំ នឹងខ្ពស់ជាងប្រាសាទទាំង ៤ ដែលមាននៅក្នុងទិសទាំង ៤ ហើយមានជណ្តើរសំរាបឡើងទៅគ្រប់ទិសទាំង ៤ ក្បាច់បម្លាក់ដែលមាននៅនឹងប្រាង្គណ៍ប្រាសាទនោះ ឃើញមានតែត្រង់កន្លែងមេទ្វារនឹងសុមទ្វារ មិនមានដេរដាសតាសពេញទាំងអស់ទេ ឯប្រាសាទនោះទោះបីមិនមានក្បាច់បម្លាក់ច្រើនមែន តែក៏គង់នៅល្អមើល ព្រោះទ្រង់ទ្រាយប្រាសាទនោះសមល្អណាស់ កាលបើក្រឡេកមើលទៅនឹងឃើញមានពណ៌ផ្លាស់រមួលបល្អ ព្រោះប្រាសាទនោះគេធ្វើដោយថ្មបាយក្រៀមលាយប្រឡំគ្នាដោយថ្មពណ៌ប្រផេះ ។


កាលបើចេញពីប្រាសាទតាកែវតាមផ្លូវខាងកើត ហើយបែតាមថ្នល់បែកទៅខាងត្បូងទៅ នឹងជល់ទៅប្រាសាទ ១ ទៀត ឈ្មោះថាប្រាសាទតាព្រហ្ម ។

ប្រាសាទតាព្រហ្ម

ប្រាសាទតាព្រហ្មនេះ គេសាងក្នុងរវាងពុទ្ធសករាជ ជាង ១៤៥០ និង ១៥០០ នៅប្រាសាទនេះយើញមានរូបបម្លាក់ដែលមានក្នុងសាសនាទាំង ២ គឺពុទ្ធសាសនាខាងមហាយាន និងសាសនាព្រាហ្មណ៍ ។

ប្រាសាទនោះសព្វថ្ងៃនេះ ស្ថិតនៅក្នុងកណ្តាលព្រៃ គេមិនទាន់តាប់ឆ្ការព្រៃធ្វើឲ្យស្អាត ដូចជាប្រាសាទឯទៀតៗនៅឡើយទេ ។

ប្រាសាទនេះប្រកបដោយកំផែង ៥ ជាន់ កំផែងខាងក្រៅបំផុត បណ្តោយពីខាងកើតទៅខាងលិច បំនួន ១០០០ ម៉ែត្រ ទទឹងពីខាងជើងទៅខាងត្បូង ប្រហែលជាជាង ៦០០ ម៉ែត្រ នៅកំផែងខាងក្រៅនេះ មានទ្វារ ៤ គ្រប់ទិសទាំង ៤ នៅខាងលើទ្វារនីមួយៗ នោះគេធ្វើក្លោងជាប្រាសាទ មានកំពូលប្រដាប់ដោយមុខ ៤ បែរទៅគ្រប់ទិសទាំង ៤ នៅត្រង់ជ្រុងទាំង ៤ នៃប្រាសាទ ទ្វារមួយៗមានរូបគ្រុឌមួយៗនៅគ្រប់ជ្រុង ឯទ្វារដែលចេញចូលបានសព្វថ្ងៃនេះ គឺទ្វារខាងកើតនឹងខាងលិច តែទ្វារខាងកើត



រូបពោធិសត្វក្នុងពុទ្ធសាសនាប៉ែកទាំងមហាយាន៧ទៅទីព្រះសាទអង្គរធ្វើដោយសំរិទ្ធ

ជាទ្វារធំ បើបួលទៅតាមទ្វារខាងកើត លុះបួលផុតពីកំផែងទី ១ ខាងក្រៅទៅ ត្រូវដើរបួលទៅតាមផ្លូវជើង ដើរបន្តិចទៅក៏ដល់ទៅផ្លូវឬ ជាផ្លូវឆ្លងកាត់ស្រែ ដែលមានទៅដោយជុំវិញកំផែងទី ២ ដើរតាមផ្លូវនោះទៅក៏ដល់ទៅទ្វារកំផែងទី ២ នៅត្រង់ទ្វារនោះគេធ្វើជាប្រាសាទមានកំពូល ហើយមានទ្វារតូច ៗ ពីរនៅសងខាងទ្វារធំ ខាងលើធ្វើជាដំបូលមានសណ្ឋានដូចរោងថែរ នៅទីសងខាងទ្វារឃើញមានរូបបម្លាក់ ត្រង់រឿងព្រះភ្លើងមារ កាលបួលផុតពីទ្វារកំផែងទី ២ ទៅ នឹងឃើញប្រាសាទ ១ បណ្តោយប្រហែលជា ៣០ ម៉ែត្រ ទទឹងប្រហែលជា ២០ ម៉ែត្រ មានសណ្ឋានដូចជាសាលា តែបាក់បែកជាច្រើនណាស់ហើយ ឃើញសល់នៅតែជញ្ជាំងនឹងសសរ នៅជញ្ជាំងខាងត្បូងនឹងខាងជើង ត្រង់កន្លែងខាងលើនឹងសងខាងទ្វារបង្អួច មានក្បាច់បម្លាក់ល្អណាស់ទៅពីនោះទៅទៀត ក៏ដល់ទៅកំផែងទី ៣ កំផែងនេះ មានសណ្ឋានជារោងថែរព័ទ្ធជុំវិញ មានទ្វារបី ៗ គ្រប់ទិសទាំង ៤ ខាងលើទ្វារគេធ្វើជាប្រាសាទមានកំពូលខ្ពស់ឡើង ប្រកបដោយក្បាច់បម្លាក់យ៉ាងល្អ លុះបួលផុតពីកំផែងទី ៣ ទៅ នឹងឃើញ

រោងថែរ៣ជួដែលជាផ្លូវប្ចូលទៅកាន់កំផែងទី៤ ហើយមានរោង
ថែរ កាត់ពីខាងត្បូងទៅខាងជើង នៅក្នុងទីផ្ទៃបន្ទោះកំផែងទី៣
នឹងទី៤ ជាសងខាងផ្លូវបែកខាងកើត ឃើញមានប្រាសាទជា
ច្រើនសុទ្ធតែមានក្បាច់បម្លាក់យ៉ាងល្អៗ នៅស៊ុមទ្វារប្រាសាទ១
ក្នុងទីផ្ទៃខាងត្បូង ឃើញរូបបម្លាក់ត្រង់រឿងព្រះប្រសូតិបាកព្រះ
ឧទរនៃព្រះនាងសិរីមហាមាយានៅព្រៃលុម្ពិនី ហើយឃើញរូប
ព្រះឥន្ទ្រនឹងរូបទេវតាជាច្រើន នៅសងខាងផ្លូវបែកខាងលិបមាន
ប្រាសាទពីរ ១ ខាងត្បូងធ្វើដោយឬពណ៌ប្រផេះ ១ ខាងជើងធ្វើ
ដោយឬបាយក្រៀម បែកទិសខាងត្បូងនឹងខាងជើង មានរោង
ថែរ២ជួ តរពីរោងថែរជាន់ទី ៣ ទៅភ្ជាប់នឹងរោងថែរជាន់ទី ៤ ។
កំផែងទី ៤ មានសណ្ឋានជារោងថែរជុំវិញ ហើយមានរោងថែរ
តរភ្ជាប់ទៅកំផែងទី ៥ ដែលមានសណ្ឋានជារោងថែរជុំវិញ ត្រង់
កណ្តាលមានប្រាសាទ ១ ធំនឹងខ្ពស់ជាងប្រាសាទទាំង ៨ ដែល
មាននៅនឹងរោងថែរជុំវិញនោះ ហើយមានរោងថែរជាប់ពីរោង
ថែរខាងកើតនឹងខាងលិប ត្រង់ទៅដល់ប្រាសាទកណ្តាល ។
នោះមានលែ្វងជា ៤ ជ្រុង ហើយមានទ្វារប្រហារគ្រប់ទិសទាំង ៤

គេអាចចេញទៅបានតាមទ្វារខាងលិច ហើយដើរតាមរោងថែរ
ត្រង់ទៅខាងលិចទៅ ។

នៅក្នុងរោងថែរប្រាសាទតាព្រហ្មនេះ ឃើញមានសិលា
ចារឹកនៅនឹងសសរឬ ១ និយាយថាស្តេចទ្រង់ព្រះនាមជ័យវរ្ម័ន
ទី ៧ បានត្រាស់បង្គាប់ឲ្យធ្លាក់សិលាចារឹកនេះ ក្នុងពុទ្ធសករាជ
១៧២៨ ព្រះអង្គសូមក្រាបថ្វាយបង្គំដល់ព្រះរត្នត្រ័យ គឺព្រះពុទ្ធ
ព្រះធម៌ ព្រះសំឃ នឹងអរិលោកិតេស្សរ ហើយនិយាយពីព្រះអង្គ
បានធ្វើសឹកសង្គ្រាមមានជ័យជំនះ នឹងនិយាយពីប្រាសាទទាំង-
ប៉ុន្មានដែលព្រះអង្គបានសាង ។

ទីប្រាសាទតាព្រហ្មនេះ ប្រសិនបើអស់លោកអ្នកទាំង
ឡាយ បានទៅមើលក្នុងវេលាយប់ ក្នុងថ្ងៃដែលមានព្រះចន្ទ
ពេញវង់ ដូចយ៉ាងក្នុងថ្ងៃ ១៥ កើត នឹងឃើញទីប្រាសាទគោះ
ល្អមើលណាស់ ប៉ុន្តែត្រូវឲ្យរកឮកគូលី ដែលស្គាល់ផ្លូវជួនជំ-
ណើរទៅផង តែត្រូវឲ្យមានចន្ទសឬបង្អៀងសំរាបបំភ្លឺផ្លូវ ក្នុង
វេលាដែលដើរកាត់ព្រៃឬលទៅ ។

បើកាលដែលឬលទៅតាមទ្វារខាងលិច នោះត្រូវចេញមក
វិញតាមទ្វារខាងកើត លុះចេញផុតពីទ្វារកំផែងខាងក្រៅមក

ហើយ ត្រូវដើរបែរទៅខាងឆ្វេងទៅ ក៏នឹងឃើញប្រាសាទបន្ទាយ-ក្តី ព្រោះប្រាសាទនោះនៅជិតគ្នា គឺត្រង់ជ្រុងកំផែងប្រាសាទតា-ព្រហ្មខាងទិសអគ្នេ នៅជិតគ្នានឹងជ្រុងកំផែងប្រាសាទបន្ទាយក្តី ខាងទិសពាយព្យ ៚—

ប្រាសាទបន្ទាយក្តី

ប្រាសាទនេះកាលដើមគេធ្វើដើម្បីឧទ្ទិសឆ្លងព្រះពុទ្ធសាសនាខាងមហាយាន សាងដំណាលគ្នានឹងប្រាសាទតាព្រហ្ម ក្នុងរាជស្នេចឈ្មោះរាជេន្ទ្រវរ្ម័ន ទី ២ ប្រហែលជាដល់មកក្នុងវាំងពុទ្ធសករាជ ២០៥០ ប្រាសាទនោះក៏បាក់បែកជាច្រើន ទាំងក្បាច់បម្លាក់នៅប្រាសាទនោះ ក៏រលេះរបកជាច្រើន ។

ប្រាសាទនេះមានកំផែងព័ទ្ធជុំវិញ នៅកំផែងនោះមានទ្វារសំរាបចេញចូលគ្រប់ទិសទាំង ៤ តែទ្វារខាងកើតជាទ្វារធំនៅលើទ្វារនោះគេធ្វើជាប្រាសាទ មានកំពូលប្រជាប់ដោយមុខ ៤ នៅត្រង់ជ្រុងទាំង ៤ នៃប្រាសាទទ្វារនោះ មានរូបគ្រុឌមួយៗនៅគ្រប់ជ្រុង ឯទ្វារដែលចេញចូលបានសព្វថ្ងៃនេះ គឺទ្វារខាងលិចនឹងខាងកើត កាលបើចូលទៅតាមទ្វារខាងកើត លុះចូលផុតទ្វារកំ

ផែងនោះទៅ ត្រូវដើរទៅតាមផ្លូវជើង ដើរបត់ចូលទៅក៏ដល់ទៅផ្លូវ
ឬ ដែលមានរូបនាគជាប្រាកាន់ដៃទាំងសងខាង ជាផ្លូវកាត់ស្រែ
ចូលទៅដល់ទៅកំផែងទី២ ដែលជាទីមានផ្ទៃជាប់គ្នារហូត
ដល់ប្រាសាទកណ្តាល នៅកំផែងទី២នេះ ខាងកើតនិងខាងលិច
មានទ្វារបីៗ សំរាប់បេញចូល ខាងលើធ្វើជាកំពូល មានភាពជា
ប្រាសាទ តរពីនោះទៅទៀតមានផ្លូវឬតរភ្ជាប់គ្នាទៅនឹងប្រាសាទ
មានរាងទ្វែរង ១ ប្រាសាទនេះមានទ្រង់សណ្ឋានដូចជាសាលា
សព្វថ្ងៃនេះបាក់បែកអស់ហើយ នៅសល់តែសសរ នឹងជញ្ជាំង
តរពីនោះទៅទៀត មានផ្លូវឬប្រែរង្វែងបំនួន ៥ម៉ែត្រតរភ្ជាប់ទៅនឹង
កំផែងទី ៣ កំផែងនោះមានសណ្ឋានជារោងថែរព័ទ្ធជុំវិញ ត្រង់
កន្លែងទ្វារគេធ្វើជាប្រាសាទ មានកំពូលខ្ពស់ឡើង ហើយមាន
រោងថែរខ្ទាត់ខ្វែងជាប់គ្នា នឹងប្រាសាទកណ្តាលៗនោះ ធំនឹង
ខ្ពស់ជាងប្រាសាទទាំង ៨ ដែលមាននៅជុំវិញ ។

នៅក្នុងទីប្រាសាទបន្ទាយក្តីនេះ ឃើញមានស្នាមកោស
លុបព្រះពុទ្ធរូបដែលគេធ្លាក់នៅសសរ ឃើញទំនងបំរុងនឹងធ្វើជា
រូបព្រាហ្មណ៍ត្រង់កន្លែងនោះខ្លះ ឃើញស្នាមកោសលុបបំបាត់

ចោលខ្លះដែលកោសលុបព្រះពុទ្ធរូបនេះប្រហែលជាពួកអ្នកកាន់សាសនាព្រាហ្មណ៍ ដែលមកនៅគ្រប់គ្រងទីនោះជាខាងក្រោយ នាំគ្នាបំផ្លាញអស់ទាំងព្រះពុទ្ធរូបនោះចេញ ។

នៅកន្លែងខ្លះ ឃើញមានរូបបម្លាក់ ត្រង់រឿងព្រះផ្ទាំញ្ញាមារ កន្លែងខ្លះ ឃើញរូបបម្លាក់ត្រង់រឿង កាលដែលគេបីព្រះសំទ្ធត្ត កាលនៅជាកុមារតូច ឲ្យទៅថ្វាយបង្គំអសិតតាបស ឬកាលទេវិលតាបស តែរូបបម្លាក់ទាំងនេះ សុទ្ធតែសល់នៅពីការបំផ្លាញរបស់ពួកព្រាហ្មណ៍ ។

នៅកន្លែងខ្លះឃើញមានស្នាមវាយបំបាក់ធំងកោសលុបរូបខាងសាសនាព្រាហ្មណ៍វិញក៏មាន ឯការបំផ្លាញរូបខាងសាសនាព្រាហ្មណ៍នេះ ប្រហែលជាពួកអ្នកកាន់ព្រះពុទ្ធសាសនា ខាងហីនយានដែលមានមកក្នុងជាន់ក្រោយនាំគ្នាបំផ្លាញរូបខាងសាសនាព្រាហ្មណ៍នោះវិញ បានជាសព្វថ្ងៃនេះឃើញមានព្រះពុទ្ធរូបខាងហីនយានជាប្រើនព្រះអង្គនៅក្នុងប្រាសាទបន្តាយក្តីនោះ.

បើកាលដែលបួលទៅក្នុងប្រាសាទនេះ តាមទ្វារខាងលិបត្រូវបេញមកវិញ តាមទ្វារខាងកើត កាលបើបេញផុតពីកំផែង

ខាងក្រៅ ហួសមកដល់ផ្លូវប្ដូលបែកទៅខាងត្បូង ត្រូវបង្ហួសត្រង់ទៅខាងកើតតាមផ្លូវជើង ដើម្បីតំងទៅមើលទីស្រះស្រង់ ។

ស្រះស្រង់

ស្រះស្រង់នេះ បណ្ដោយពីខាងលិចទៅខាងកើត បំនួន ៣០០ម៉ែត្រ នៅបំពីខាងមុខប្រាសាទបន្តិចក្ដី ហើយនៅជិតតំងផ្លូវប្ដូល នៅខាងលិចស្រះនេះ មានទីលានឬ ១ មានជណ្ដើរសំរាបបុះទៅកាន់ស្រះ ហើយមានរូបនាគជាប្រកាន់ដៃផង បើឡើងទៅលើទីលានឬនោះ ក្នុងវេលាដែលព្រះអាទិត្យរៀបតំងអស្ដង្គតហើយ មើលទៅស្រះនោះ ឃើញល្អមើលណាស់ ។

នៅខាងត្បូងទីលានឬនោះ មានសាលាប្រកក្បឿង ១ ស្អាតបាត គេទើបតំងធ្វើ ដើម្បីប្រយោជន៍ដល់អស់អ្នកដំណើរដែលត្រូវការ តំងប្ដូលទៅឈប់សំរាក ឬបរិភោគអាហារ ។

កាលបើផុតសេចក្ដីត្រូវការតំងមើលទីស្រះស្រង់នោះហើយ បើអស់អ្នកដំណើរមានពេលតិច ត្រូវការតំងវិលត្រឡប់ទៅវិញឆាប់ នោះប្ដូរត្រឡប់ទៅវិញតាមផ្លូវប្ដូលដែលបែកទៅខាងត្បូង

ប៉ុះព្រោះផ្លូវនោះវង់ធៀងទៅខាងលិចត្រង់ទៅលើអង្គរវត្ត បើទៅតាមផ្លូវនោះនៅបំនួនជាង ៤០០០ ម៉ែត្រទៀត នឹងដល់ទៅអង្គរវត្ត នឹងក្រឡេកទៅឃើញប្រាសាទ ១ ឈ្មោះថាប្រាសាទក្រវាញ នៅជាខាងឆ្វេងដៃ ជាប្រាសាទផ្លែកអំពីប្រាសាទឯទៀតៗ គួរតែឈប់ឫលទៅមើលមួយស្របក់សិន ។

ប្រាសាទក្រវាញ

ដៃលនឹងដើរពីថ្នល់ទៅកាន់ប្រាសាទក្រវាញនេះ ដើរទៅបានតែក្នុងរដូវខែប្រាំង លុះដល់រដូវខែវស្សា មានទឹកភ្លៀងច្រើនពេនដើរទៅមិនបានទេ ព្រោះមានទឹកជក់នៅក្នុងស្រះដៃលមាននៅជុំវិញប្រាសាទនោះ ។

ប្រាសាទក្រវាញនេះគេសាងប្រហែលក្នុងរវាងពុទ្ធសករាជ ១៤៣០ ដើម្បីទុទ្ទិសឫប្បាយដល់សាសនាព្រាហ្មណ៍ ប្រាសាទនោះមាន ៥ ស្ថិតនៅជាជួរត្រង់ពីខាងជើងទៅខាងត្បូង តែសព្វថ្ងៃនេះសល់នៅតែ ៤ ព្រោះប្រាសាទ ១ ខាងជើងបាក់បែកអស់ហើយ ប្រាសាទទាំងនោះគេធ្វើដោយឥដ្ឋទាំងអស់ រឿរលែងតែត្រង់កន្លែងទ្វារនឹងស៊ុមទ្វារគេធ្វើដោយថ្ម ប្រាសាទទាំង ៤ នោះ

សុទ្ធតែមានទ្វារតែមួយ ។ ពីខាងកើត ប្រាសាទកណ្តាលធំនឹង
ខ្ពស់ជាងប្រាសាទទាំងសងខាង នៅសុំទ្វារប្រាសាទទាំង ៤ នោះ
មានក្បាច់បម្លាក់ល្អណាស់ នៅប្រាសាទកណ្តាលត្រង់ជញ្ជាំង
ឥដ្ឋខាងក្រៅសងខាងទ្វារ ឃើញបម្លាក់រម្លេចរូបទ្វារបាល គឺអ្នក
រក្សាទ្វារ ខាងក្នុងប្រាសាទកណ្តាលត្រង់ជញ្ជាំងខាងត្បូង ឃើញ
បម្លាក់រម្លេចរូបវិស្ណុមានដៃ ៤ ជញ្ជាំងខាងជើងឃើញបម្លាក់រម្លេច
រូបវិស្ណុដេះលើគ្រុឌ ជញ្ជាំងខាងក្រោយឃើញរូបទេវតា ១ មាន
ដៃ ៨ ។

កាលបើមើលប្រាសាទក្រវាញនេះរួចហើយ ត្រូវទៅតាម
ផ្លូវប្ញស់ត្រង់ទៅអង្គរវត្តតាមសេបក្តីប្រាប់ចុះ ។

បើអស់អ្នកដំណើរមានពេលប្រើន មិនប្រញាប់ធំនឹងត្រឡប់
វិញទេ កាលបើមើលទីស្រះស្រង់រួចហើយ ត្រូវទៅតាមផ្លូវប្ញស់
បែកទៅខាងជើង ទៅតែបន្តិចទៅក៏ជួបនឹងផ្លូវប្ញស់ ដែលមកពី
ខាងលិចត្រង់ទៅឯកើត ហើយត្រូវទៅតាមផ្លូវប្ញស់នោះតាមក្បែរ
មាត់ស្រះស្រង់ត្រង់ទៅខាងកើតដល់ទៅកន្លែងដែលបត់ទៅខាង
ជើងនៅត្រង់ជ្រុងផ្លូវបត់នោះមានប្រាសាទ ១ ឈ្មោះបាប្រាសាទ
ប្រែរូប ។

ប្រាសាទប្រែរូប[1]

ប្រាសាទប្រែរូបនេះ គេសាងប្រហែលក្នុងរវាងពុទ្ធសករាជ ១៥៥០ ដើម្បីឧទ្ទិស្សឫទ្ធិយសសាសនាព្រាហ្មណ៍ ។

ប្រាសាទនេះមាន ៣ ជាន់ ក្នុងកំផែងទី ១ និងទី ២ សព្វថ្ងៃនេះ លំបាកចូលទៅណាស់ ព្រោះគេមិនទាន់រៀបបំផ្លេឲ្យស្អាតនៅឡើយ ដោយមានព្រៃជុំជាសពាសក្នុងកំផែងទាំង ២ ជាន់ ឃើញមានប្រាសាទជាប្រើនក្នុងកំផែងទាំង ២ ជាន់នេះ តែបាក់បែកជាប្រើន ត្រង់ជាន់កណ្តាលមានសណ្ឋានជាតួប្រាង្គណ៌ខ្ពស់ ទ្បើង ៣ ហ្នឹក់ មានជណ្តើរនៅស្តុ សំរាបទ្បើងទៅជាន់លើទីផ្ទៃខាងលើ នៅមាត់ជណ្តើរមួយៗ សុទ្ធតែមានរូបសត្វសីហនៅជាសងខាង នៅទីផ្ទៃខាងលើមានប្រាសាទ ៥ គឺប្រាសាទ ១ នៅបំពាក់កណ្តាល មានទំហំធំនិងខ្ពស់ជាងប្រាសាទទាំង ៤ ដែលមាននៅក្នុងជ្រុងទាំង ៤ ប្រាសាទកណ្តាលនោះ មានជណ្តើរ ៤ សំរាបទ្បើងគ្រប់ទិសទាំង ៤ ប្រាសាទទាំង ៥ នោះ មានទ្វារបួល

---

(១) តាមរឿងព្រេងនិយាយថា ប្រាសាទនេះបានជាឈ្មោះថា ប្រែរូប ព្រោះកាលតំណើមគេបានប្តូរជាសត់ស្តេច ១ អង្គ ត្រង់កន្លែងប្រាសាទនេះ ។

ទៅបានតែខាងទិសឯកើត ឯទិសទាំង ៣ ប្លែទៅមិនបានទេ ព្រោះបិតជិតគ្រាន់តែមានភាពទំនងជារាងទ្វារ ហើយមានក្បាច់បម្លាក់យ៉ាងល្អនៅគឹងកន្លែងទ្វារទាំង ៣ ទិសនោះ ។

ឯប្រាសាទទាំងអស់ក្នុងទីប្រាសាទប្រែរូបនេះ គេធ្វើដោយឥដ្ឋឈាយនឹងឥដ្ឋ ។

កាលបើចេញពីប្រាសាទប្រែរូបមក ត្រូវទៅតាមផ្លូវឥដ្ឋល់ត្រង់ទៅខាងជើងទៅ បំនួន ១៤០០ ម៉ែត្រ ក៏នឹងឃើញប្រាសាទ ១ ទៀត នៅជាខាងលិចឥដ្ឋល់ ឈ្មោះថាប្រាសាទមេបុណ្យ ឯប្រាសាទមេបុណ្យនោះ មានទំនងបៃបផែនដូចគ្នានឹងប្រាសាទប្រែរូបដែរ ប្លែកបន្តិចតែប្រាសាទមេបុណ្យនេះ មានរូបដំរីនៅត្រង់ជ្រុងខឿនខាងក្រោម ។

លុះទៅឥតពីនោះទៀតក៏ដល់ទៅស្ពានឬទ្ធិ ដែលគេធ្វើដោយស៊ុមដំនៅស្ទឹងសៀមរាប ឥតពីស្ពាននោះតែបន្តិចទៅ ក៏នឹងឃើញប្រាសាទ ១ នៅជាខាងកើតឥដ្ឋល់ ឈ្មោះថាប្រាសាទតាសោម ល្អ—

ប្រាសាទតាសោម

ប្រាសាទតាសោមនេះ គេសាងប្រមៀលក្នុងរវាងពុទ្ធសករាជ ១៣៥០ ដើម្បីឧទ្ទិសប្បូជនីយវត្ថុព្រះពុទ្ធសាសនាខាងមហាយាន ។

ដែលនឹងចូលទៅកាន់ប្រាសាទនោះ សព្វថ្ងៃនេះចូលទៅបានតែតាមទ្វារខាងលិច ព្រោះទ្វារនោះនៅជិតផ្លូវប្តូល ។

ប្រាសាទនេះមានកំផែងព័ទ្ធជុំវិញ នៅកំផែងនោះមានទ្វារ ៤ គ្រប់ទិសទាំង ៤ ទ្វារមួយ ៗ គេធ្វើមានកំពូលមានសណ្ឋានដូចជាប្រាសាទប្រជាប់ដោយមុខ ៤ ។

កាលបើចូលទៅតាមទ្វារខាងលិច ចូលផុតកំផែងទី ១ ទៅហើយដើរបន្តិចទៅ ក៏ដល់ទៅផ្លូវប្តូដែលឆ្លងកាត់ស្រះ លុះដើរតាមផ្លូវនោះទៅក៏ដល់ទៅកំផែងទី ២ ទៅផុតពីកំផែងទី ២ នោះទៅក៏ដល់ទៅកំផែងទី ៣ កំផែងទី ៣ នេះ គេធ្វើមានសណ្ឋានជារោងបៃវង្សជុំវិញប្រាសាទកណ្តាលៗនោះ មានទំហំធំធំងខ្ពស់ជាងប្រាសាទទាំង ៨ ដែលមាននៅជោយជុំវិញ នៅខាងមុខប្រាសាទកណ្តាលមានបណ្ណាល័យ ២ នៅសងខាងផ្លូវ ។

ប្រាសាទនោះសព្វថ្ងៃនេះ លំបាកចូលទៅណាស់ ព្រោះមានព្រៃធំឯជើមឈើធំៗ ជុះជាសភាសក្នុងប្រាសាទនោះ ជួបត្រង់ទ្វារខាងលិច មានជើមឈើធំ១ជើម ជុះពីខាងលើទ្វារហើយមានឫសជុះបាក់ចំពីកំពូលក្លោងទ្វារ ជិរាបដល់ផែនដី ទាំងឬក៏ធ្លាក់រាត់រាយជេរជាសក្នុងទីនោះ គេមិនទាន់រៀបចំឲ្យស្អាតល្អនៅឡើយ ។

កាលបើចេញពីប្រាសាទតាសោមនេះមក ត្រូវទៅតាមផ្លូវឬស្ថលត្រង់ទៅខាងជើង ទៅតែបន្តិចទៅ ក៏បត់តាមផ្លូវឬស្ថល ត្រង់ទៅខាងលិចទៅ បំនួនប្រហែលជា ២ គីឡូម៉ែត្រ នឹងឃើញផ្លូវជើង ១ នៅជាខាងជើងផ្លូវ ហើយដើរតាមផ្លូវនោះ កាត់ព្រៃបន្តិចទៅ នឹងឃើញប្រាសាទ ១ នៅក្នុងព្រៃ ឈ្មោះជាប្រាសាទក្រាលគោ ⁂—

ប្រាសាទក្រាលគោ

ប្រាសាទក្រាលគោនេះជាប្រាសាទតូចណាស់ សព្វថ្ងៃនេះបាក់បែកជាច្រើនណាស់ហើយ ដែលនឹងចូលទៅមើលប្រាសាទនេះ ត្រូវចូលទៅតាមផ្លូវខាងកើត រូបចម្លាក់មាននៅនឹងប្រាសាទ

នោះ សង្កេតមើលទៅឃើញមានរូបបម្លាក់ ខាងព្រះពុទ្ធសាស-
នាខាងមហាយានក៏មាន ខាងសាសនាព្រាហ្មណ៍ក៏មាន ។

កាលចេញពីប្រាសាទនេះមកវិញ ត្រូវទៅតាមផ្លូវប្តូលត្រង់
ទៅខាងលិច ទៅតែបន្តិចទៅក៏ឆ្លងឃើញប្តូល ១ ផ្សែង នៅជា
ខាងឆ្វេងដៃ ជាប់ពីផ្លូវប្តូលបែកត្រង់ទៅប្រាសាទនាគព័ន្ធ ៙—

ប្រាសាទនាគព័ន្ធ

ប្រាសាទនេះ គេធ្វើជើម្បីឧទ្ទិសឆ្លាយដល់អរិលោកិតេស្វរ
បានជាដឹងដូច្នេះ ដឹងដោយការស្នាដៃរបស់អ្នកប្រាជ្ញបារាំងម្នាក់
ឈ្មោះ ល្វី-ហ្វីណូត លោកនេះបានទៅពិនិត្យសង្កេតមើលនៅទី
នោះ ហើយបានដឹងប្រាកដថា ជាគេធ្វើជើម្បីឧទ្ទិសឆ្លងដល់ព្រះ
អរិលោកិតេស្វរ ដោយមានគ្រឿងតិកតាង ល្មមឲ្យសង្កេតទៅ
ជឿបាន ដោយឥតមានសង្ស័យ ។

ប្រាសាទនោះមានកំផែងព័ទ្ធជុំវិញ នៅក្នុងកំផែងនោះមាន
ស្រះធំ ៤ ជ្រុង ១ នៅបំពាក់កណ្តាល ហើយមានស្រះតូច ៗ នៅ
គ្រប់ទិសទាំង ៤ ស្រះទាំង ៥ នោះសុទ្ធតែមានឮគេរៀបជាប្លាក់ ៗ

ជាជណ្តើរជុំវិញ តាំងពីមាត់ស្រះសំរាប់ចុះទៅក្នុងស្រះ ត្រង់កណ្តាលស្រះធំ មានទីផ្ទៃដីរាងមូលខ្ពស់ឡើង មានសណ្ឋានដូចជាកោះ ហើយមានឬកេរៀបជាហ្មក់ ។ ជាជណ្តើរសំរាប់ចុះទៅក្នុងស្រះ ឯប្រាសាទដែលនិយាយពីខាងដើមនោះ ស្ថិតនៅបំពីខាងលើទីដីកណ្តាលស្រះធំនោះឯង ហើយមានជើមត្រាង ១ ជើម ដុះបំពីខាងលើប្រាសាទ មានឫសដុះព័ទ្ធព័ន្ធប្រាសាទនោះដោយជុំវិញ មែកត្រាងនោះដែលធ្លាក់សំយោកគ្របពីលើ មានសណ្ឋានដូចជាធ្នឹបាំងពីខាងលើ ។

ទីផ្ទៃដីដែលទ្រប្រាសាទនោះ មានសណ្ឋានដូចជាស្រទាប់ផ្កាឈូក ត្រង់កន្លែងខាងលើជណ្តើរ ទីខាងក្រោមមានរូបនាគ ២ កន្ទុយចាក់ទៅខាងលិចព័ទ្ធព័ន្ធគ្នាត្រចៀងត្រង់ឡើង ដូចកន្ទុយនាគតែ ១ ក្បាលមកខាងកើត ព្រោះហេតុនេះបានជាគេហៅថាប្រាសាទនាគព័ន្ធ ។

នៅក្នុងស្រះនោះ ត្រង់ទីជុំវិញប្រាសាទ កាលពីដើមមានទឹកដក់នៅជានិច្ច ទឹកនោះគេប្រើនរាប់អានដោយសំគាល់ថា ជាទឹកមានអានុភាពពូកែណាស់ ។

នៅប្រាសាទនោះ ត្រង់ទីខាងក្រោមឃើញមានឋ្នាក់ ជាដុំឈូកទ្រ ត្រង់ទីជញ្ជាំងខាងលើទ្វារខាងកើតនឹងខាងជើង មិនមានឫសឈើព័ទ្ធព័ន្ធទ្បើយ ម្ល៉ោះហើយគេមើលទៅឃើញក្បាច់រម្លេច ត្រង់រឿងកាលព្រះសិទ្ធត្ថកាត់ព្រះកេសា ទៀបឆ្នេរស្ទឹងអនោមានទី នឹងកាលដែលអាមាត្យឈ្មោះឆន្ន នាំសេះកណ្ឋកត្រឡប់ទៅព្រះរាជវាំងវិញ ត្រង់កន្លែងទ្វារនៅជញ្ជាំងខាងជើងនឹងខាងលិច ឃើញមានរូបអរិលោកិតេស្សរ ព្រមទាំងគ្រឿងប្រដាប់របស់អរិលោកិតេស្សរនោះផង ត្រង់កន្លែងទ្វារនៅជញ្ជាំងខាងត្បូង ឃើញមានរូបអរិលោកិតេស្សរ ហើយឃើញរូបព្រះអាទិត្យនឹងព្រះបន្ទ កំពុងតែនមស្សការទៅអរិលោកិតេស្សរនោះ ឯក្បាច់បម្លាក់ទាំងនោះ សុទ្ធតែក្បាច់បម្លាក់យ៉ាងល្អ ៗ ។

នៅក្នុងស្រែត្រង់កន្លែងជិតជើងជណ្តើរខាងកើត គេជីកដីទៅឃើញដែនឋ្ម ១ ឋ្មនោះគេធ្លាក់ជារូបមនុស្សមានចំនួនប្រើនតោងរូបសេះ រូបទាំងនេះតាមលោក ល្វី-ហ្វីណូត យល់ថាជារូបគេធ្វើបំពោះ ត្រង់រឿងកាលព្រះអរិលោកិតេស្សរ ដំណែងខ្លួនជាសេះពលាហក ទៅស្រែងអស់ទាំងមនុស្ស ដែលលង់ទឹកនៅតា

កោះរក្សសី ឯនៅក្នុងស្រុកខ្មែរគេអាចដឹងបាន ថាតែអរិលោកិតេ-
ស្សរ ដំណែងខ្លួនជាសេះពលាហក ព្រោះនៅរឹមានអាកាសមាន
សិលាចារឹកជាភាសាសំស្ក្រឹត និយាយថាលោកេស្សរដំណែងខ្លួន
ជាសេះពលាហក ផែនឋ្មៃដែលគេធ្លាក់ ជារូបមនុស្សតោងសេះ
នោះ ជាបម្លាក់ល្អណាស់ គួរនឹងរាប់ទុកថាជាបម្លាក់យ៉ាងល្អសំ-
ខាន់ ១ យ៉ាង ។

នៅស្រែធំមានកន្លែង ៤ ជាប្រហោងតូចៗ សំរាបចាក់ទឹក
បង្ហូរទៅក្នុងស្រែតូចទាំង ៤ ត្រង់កន្លែងប្រហោងនោះគេធ្លាក់ឬធ្វើ
ឲ្យមានសណ្ឋានដូចដង្កៀឈូក កាលបើចាក់ទឹកទៅ ទឹកនឹងហូរ
ធ្លាក់បុះទៅកាន់ស្រែទាំង ៤ តាមឬដែលគេធ្វើឲ្យមានសណ្ឋាន
ជាក្បាលផ្សែងៗគ្នា គឺខាងកើតជាក្បាលមនុស្ស ខាងត្បូងជា
ក្បាលសត្វសីហ ខាងលិចជាក្បាលសត្វតែមឹនប្រាកដជាសត្វអ្វី
(តាមសៀវភៅបិណ្ឌចារវិនាក្ខន គេនិយាយថាជាក្បាលគោ) ខាង
ជើងជាក្បាលដំរី នៅត្រង់កន្លែងមួយៗនោះ មានប្រាសាទតូចៗ
គ្របពីលើ ។

នៅនឹងប្រាសាទតូចៗទាំង ៤ នោះ កន្លែងខ្លះឃើញមាន
រូបបម្លាក់អរិលោកិតេស្សរ ដែលកំពុងធ្វើសេចក្តីសង្គ្រោះ ដល់

មនុស្ស ឲ្យបានរូបពីសេបក្តីទុក្ខលំបាក មានជម្ងឺជម្កាត់ជាដើម កន្លែងខ្លះឃើញមានរូបបម្លាក់អរិលោកិតេស្សរ ហើយឃើញមានរូបមនុស្សកំពុងតែនមស្សការ កន្លែងខ្លះឃើញតែលិង្គព្រះឥស្សរ ប៉ុន្តែសង្កេតមើលទៅឃើញមានស្នាមកោសលុបត្រង់កន្លែងនោះនេះប្រហែលជាពួកអ្នកកាន់សាសនាព្រាហ្មណ៍នាំគ្នាកោសលុបរូបអរិលោកិតេស្សរចេញ ហើយធ្វើលិង្គព្រះឥស្សរជាក់ត្រង់កន្លែងនោះវិញ ។

កាលបើចេញពីប្រាសាទនាគព័ន្ធមកវិញ ត្រូវចេញមកតាមផ្លូវដែលលុះដល់មកផ្លូវប្តូរ ត្រូវទៅតាមផ្លូវនោះត្រង់ទៅខាងលិច ទៅតាមផ្លូវនោះទៅ នឹងឃើញផ្លូវជើង ១ នៅជាខាងឆ្វេងផ្លូវ បែកចូលទៅកាន់ទ្វារកំផែងខាងជើង នៃប្រាសាទព្រះខាន់ ៙—

ប្រាសាទព្រះខាន់

ប្រាសាទព្រះខាន់នេះ មានស្រះព័ទ្ធជុំវិញពីខាងក្រៅ តរពីស្រះទៅមានកំផែងព័ទ្ធជុំវិញទៀត កំផែងនោះបណ្តោយ ៨០០ ម៉ែត្រ ទទឹង ៧៤០ ម៉ែត្រ នៅក្នុងកំផែងនោះមានប្រាសាទជា



ក្បោងទ្វារប្រាសាទអង្គរធំ
គេទុំស្បូវថ្វាយដល់ពុទ្ធសាសនាប្អែកខាងមហាយាន
ត្រូងមារវិជ័យ

ប្រែន ជាទីធំណាស់ដែរ ប្រហែលជាកាលពីដើមទីព្រះខាន់នេះ ជាទីវាំង ១ គេសាងក្នុងរាជស្នេហឈ្មោះជយវរ៉ាមន៍ទី ២ ប្រហែលក្នុងពុទ្ធសករាជជាង ១៣៥០ ។

តាមដែលគេបានទៅពិនិត្យមើល អស់ទាំងរូបបម្លាក់ធំងសិលាចារឹកនៅទីប្រាសាទនោះ គេអាចស្មានបានថាទីប្រាសាទនេះ កាលពីដើមជាទីមានសាសនាព្រាហ្មណ៍ ព្រោះគេឃើញរូបបម្លាក់ជារូបវិស្ណុ រូបសិវធំងរឿងរាមាយណ ។ ល ។

ទីប្រាសាទព្រះខាន់សព្វថ្ងៃនេះ គេមិនអាចធំងសង្កេតពិនិត្យមើលហើយកំណត់ឲ្យប្រាកដបានទេឡើង ព្រោះប្រាសាទក្នុងទីនោះបាក់បែកជាប្រើនណាស់ ហើយព្រៃដុះពេញពាសដែរជាសក្នុងទីនោះផង ។

ដែលធំងបួលទៅកាន់ទ្វារកំផែងខាងក្រៅនោះ មានផ្លូវ ៤ ឆ្លងកាត់ស្រះបួលទៅគ្រប់ទិសទាំង ៤ តែផ្លូវទៅស្រុលសព្វថ្ងៃនេះគឺផ្លូវខាងលិបធំងខាងជើង-ព្រោះផ្លូវទាំង ២ ទិសនេះ ជាប់ពីផ្លូវប្តល់ទៅដរាបដល់កំផែងខាងក្រៅ ។ នោះ គេធ្វើដោយឬបាយ-ក្រៀម រឿរលែងតែត្រង់កន្លែងទ្វារគេធ្វើដោយឬពណ៌ប្រផេះ ។

នៅកំផែងខាងក្រៅនោះ មានទ្វារសំរាប់ចេញចូលគ្រប់ទិសទាំង ៤ ក្នុងទិសមួយ ៗ មានទ្វារបី ៗ នៅទ្វារទាំង ៤ ទិសនោះ គេធ្វើឲ្យមានសណ្ឋានជាឆ្លុះប្រាសាទទាំងអស់ ត្រង់ទីសងខាងទ្វារ គេធ្វើជារូបគ្រុឌចាប់នាគ ជារូបធំ ៗ ធ្វើដោយឥដ្ឋ ដាក់ភ្ជាប់ទៅនឹងកំផែងនោះ ម្ខាង ៗ រូបគ្រុឌមួយ ៗ ។

កាលបើចូលផុតពីកំផែងខាងក្រៅទៅ ហើយដើរចូលទៅនឹងឃើញកំផែង នឹងរោងបៃវ៉ាត់ខ្វែងជាច្រើន ទាំងប្រាសាទក៏ឃើញមានច្រើន នៅប្រាសាទខ្លះ ឃើញមានបម្លាក់រម្លេចរូបល្ខោននៅត្រង់មេទ្វារ ប្រាសាទទាំងអស់នោះ សុទ្ធតែមានក្បាច់បម្លាក់យ៉ាងល្អ ៗ ។

ក្នុងទីប្រាសាទព្រះខាន់នេះ យើងមិនអាចនឹងរៀបរាប់ឲ្យហ្មត់ចត់សព្វគ្រប់បានឡើយ ព្រោះប្រាសាទក្នុងទីនោះទាំងអស់បាក់បែកជាច្រើនណាស់ ហើយដុំឥដ្ឋក៏ធ្លាក់រាត់រាយដេរដាសប្រកេរលើគ្នា លំបាកនឹងដើរចូលទៅណាស់ ដើរជាន់តែលើគំនរឥដ្ឋទាំងព្រៃក៏ដុះស្កុកស្កុកស្មាញបង្អៀត ព្រោះគេមិនទាន់បានរៀបបំទីនោះឲ្យស្អាតល្អនៅឡើយ ហេតុនេះបានជាយើងមិនអាចនឹងដើរចូលទៅពិនិត្យឲ្យឃើញសព្វកន្លែងបាន ។

បើកាលដែលបួលទៅតាមទ្វារខាងជើង ដល់ត្រឡប់មកវិញ ត្រូវចេញមកតាមទ្វារខាងលិច លុះមកដល់ផ្លូវឬស្ស៊ីខាងលិច ត្រូវទៅតាមផ្លូវនោះ រហូតមកដល់ទ្វារអង្គរធំខាងជើង ហើយទៅតាមផ្លូវនោះ កាត់ទីអង្គរធំត្រង់ទៅខាងត្បូងទៅ គឺងដល់ទៅមុខទីព្រះលានស្នេច គឺងដល់ទីមុខបាយ័ន ហើយកាត់ទៅតាមផ្លូវត្រង់ទៅខាងត្បូង ដរាបដល់ចេញពីទ្វារអង្គរធំខាងត្បូង លុះទៅតាមផ្លូវនោះទៅ ដល់ទៅភ្នំបាក់ខែង ដល់ទៅផ្លូវឬស្ស៊ីដែលបត់បួលទៅអង្គរវត្ត ដល់ទៅផ្ទះសំណាក់ (ប៊ុង្គាឡូ) ដរាបដល់សៀមរាប ។

បើអស់អ្នកដំណើរ មានប្រាថ្នាចង់មើលទ្រង់ទ្រាយអង្គរវត្តពីខាងកើត ក៏បួរទៅតាមផ្លូវឬស្ស៊ី ១ ដែលកាត់ត្រង់ទៅខាងកើត គឺងបានឃើញទ្រង់ទ្រាយអង្គរវត្ត ហើយគឺងបានឃើញផ្កាឈូកដែលនៅក្នុងស្រះល្អមើលណាស់ រួចហើយសឹមត្រឡប់ទៅសៀមរាបតាមសេចក្តីប្រាថ្នាបុះ ។

CENTRALE DU CAMBODGE